**BMI0131**

# សម្ភាសជាមួយឈ្មោះ ធីម ណម ភេទស្រី អាយុ៥៧ឆ្នាំ

## មុខងារខ្មែរក្រហមៈ «ប្រធានក្រុមកងចល័តតំបន់៥»

## កើតនៅភូមិប៉ោយក្លឿង ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

## រស់នៅភូមិប៉ោយក្លឿង ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១

## សម្ភាសន៍ដោយៈ ឡុង ដានី

## ០១:០១:០៦

## ៣៣ទំព័រ

ដានី : ដំបូងមីងខ្ញុំចង់ស្គាល់ឈ្មោះមីងៗឈ្មោះអីដែរ?

ណម : ឈ្មោះ ណម នោះឯង។

ដានី : ឈ្មោះអីណម?

ណម : ធីម ណម។

ដានី : ធីម ណម?

ណម : ចា៎!

ដានី : អាយុប៉ុន្មានហើយមីង?

ណម : ខ្ញុំ៥៧ហើយ។

ដានី : ៥៧ឆ្នាំ។ មីងរស់នៅភូមិឃុំអីដែរសព្វថ្ងៃ?

ណម : ភូមិប៉ោយក្លឿង ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ស្រុកកំណើតកើតទីនៅនេះ។

ដានី : ភូមិប៉ោយក្លឿង ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ?

ណម : បន្ទាយមានជ័យ។

ដានី : ចុះប្ដីមីង គាត់ឈ្មោះអី ពូគាត់ឈ្មោះអី?

ណម : ឡាច ផន។

ដានី : គាត់អាយុប៉ុន្មានដែរ?

ណម : ៥០ប៉ុន្មាន ប្អូនខ្ញុំ២ឆ្នាំ ៥៥។

ដានី : មីងមានកូនចៅប៉ុន្មាននាក់ដែរ?

ណាម ៖ កូន៤ ។

ដានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ណាម ៖ ស្រី១ ប្រុស៣ ។

ដានី ៖ ចុះមីងប្រកបមុខរបររកស៊ីធ្វើអីដែរឥឡូវ?

ណាម ៖ របររកស៊ីចាប់ចាប ស្រែក៏ធ្វើ សាកអាគុយក៏សាក ។

ដានី ៖ ធ្វើស្រែលក់ដូរទៀត?

ណាម ៖ ចា៎!

ដានី ៖ លក់ដូរនឹង?

ណាម ៖ ចា៎!

ដានី ៖ ចុះមីងឪពុកមីងគាត់ឈ្មោះអីទៅ?

ណាម ៖ ឪពុកខ្ញុំស្លាប់តាំងពីខ្ញុំមិនទាន់ស្គាល់មុខ ។

ដានី ៖ ឪពុក?

ណាម ៖ ឈ្មោះ លិញ ប៊ុន លិញ ។ អូ!ខុសហើយតើ យកជីតា យកឪ ប៊ុនខាងម្ដាយ ធីម លិញ ។

ដានី ៖ ចុះម្ដាយ?

ណាម ៖ ប៊ុន ឈឿន ម៉ែខ្ញុំនៅសព្វថ្ងៃ អាយុ៨០ជាងហើយ ។

ដានី ៖ គាត់នៅរស់ទេ ។ នៅរស់នៅភូមិនឹងដែរ?

ណាម ៖ ចា៎! នោះម៉ែខ្ញុំនៅនេះ ។

ដានី ៖ ចុះមីង ស្រុកកំណើតនៅណាដែរ?

ណាម ៖ ស្រុកខ្ញុំក៏នៅនេះ ។

ដានី ៖ មីងបងប្អូនបង្កើតប៉ុន្មាននាក់?

ណាម ៖ បងប្អូន៧នាក់ ងាប់ម្នាក់ នៅសល់៦ ។

ដានី ៖ បងប្អូនទាំងអស់៧នាក់ ស្លាប់ម្នាក់?

ណាម ៖ ចា៎! ស្លាប់តែមួយ ។

ដានី ៖ ស្រីប៉ុន្មានប្រុសប៉ុន្មាន?

ណាម ៖ បងប្អូនខ្ញុំ ប្រុស២ ស្រី៥ ។

ដានី ៖ ៧នាក់ ប្រុស២នាក់ ស្រី៥?

ណាម ៖ សព្វថ្ងៃនៅសល់ប្រុសតែមួយទេ ប្រុស១ស្លាប់ហើយ ។

ដានី ៖ ឥឡូវស្លាប់ប្រុសមួយនៅសល់ប្រុសតែម្នាក់ទេ?

ណាម ៖ ចា៎!

ដានី ៖ ចុះមីងកូនទីប៉ុន្មាន?

ណាម ៖ ខ្ញុំកូនទី៥ ហ៎ទី៦ ។

ដានី ៖ កូនទី៦ ?

ណាម ៖ ចា៎!

ដានី ៖ ចឹងមីងកាលពីក្មេងៗ មីងរៀនសូត្រដល់ណាដែរ?

ណាម ៖ មិនមានការសិក្សាខ្ពស់ទេ ថ្នាក់ពី៨កាលពីសម័យដើម អត់មានឪពុក ឋានៈខ្ញុំក្រ ។

ដានី ៖ រៀនបានថ្នាក់ទីប៉ុន្មាន?

ណាម ៖ ថ្នាក់ទី៨ពីជំនាន់ដើម ។

ដានី ៖ រៀននៅសាលាណា?

ណាម ៖ សាលាព្រះនេត្រព្រះនេះឯង ។

ដានី ៖ ទី៨ សាលាព្រះនេត្រព្រះ?

ណាម ៖ ចា៎!

ដានី ៖ កាលនឹងមីងឈប់ឆ្នាំណា ថ្នាក់ទី៨នឹង?

ណាម ៖ ទេ! ឈប់យូរគ្រាន់ហើយ មើលខ្ញុំរៀន ។

ដានី ៖ ឈប់មុនរដ្ឋប្រហារ ហើយក៏?

ណាម ៖ ឈប់មុនៗ ។

ដានី ៖ មុនរយៈពេលប៉ុន្មានឆ្នាំ មុន?

ណាម ៖ ទេ! ខ្ញុំឈប់ពីឆ្នាំ៧០ ខ្ញុំរៀនឆ្នាំ៦៦ដល់៧០ ខ្ញុំឈប់ហើយ រៀនបាន៤ឆ្នាំ ខ្ញុំចាំបាន ឆ្នាំ៦៦ ៧០ខ្ញុំឈប់ហើយ ខ្ញុំឈប់ខ្ញុំធ្វើស្រែចំការដល់បានឆ្នាំ៧៥ បានខ្ញុំបានចូលបដិវត្ត ។

ដានី ៖ ចឹងដល់ពេលឈប់ឆ្នាំ៧០នឹង មកធ្វើអី?

ណាម ៖ ធ្វើតែស្រែចំការ ។

ដានី ៖ ធ្វើស្រែជាមួយពីណាទៅ?

ណាម ៖ ជាមួយបងខ្ញុំ ជាមួយម្តាយនៅ...(ស្តាប់មិនបាន) មានបងប្អូនធ្វើស្រែ ។

ដានី ៖ ជាមួយម្តាយ និងបងប្អូន?

ណម :　ចា៎! ដែលនៅលីវៗ គេមានគ្រួសារអស់ បានគេបែកអស់ទៅ។

ដានី :　ធ្វើស្រែរហូតដល់ឆ្នាំណា?

ណម :　រហូតមកលោះសព្វថ្ងៃនឹង ជីវភាព។

ដានី :　អត់ទេ ធ្វើស្រែរហូតដល់ប៉ុលពតចូល ឬក៏ មុន?

ណម :　ទេ! ធ្វើឡើងទល់ប៉ុលពតចូល គេនាំចល័តបណ្តោយ។

ដានី :　រហូតដល់ឆ្នាំ៧៥ចឹង?

ណម :　ចា៎!

ដានី :　ដល់ពេលប៉ុលពតចូលឆ្នាំ៧៥ ធ្វើអីគេទៀតទៅ?

ណម :　គេនារី គេឲ្យយើងខាងកងចល័តលើកទំនប់ ជីកប្រឡាយ កន្លែង។

ដានី :　ចូលឆ្នាំ៧៥ មឹងគេឲ្យចូលខាង?

ណម :　ចល័ត កាលនឹងគេហៅនារីចល័ត កាលនោះខ្ញុំនៅនារី។

ដានី :　ចូលខាងនារីចល័តរបស់ស្រុក ហើយក៏របស់ឃុំ របស់អី?

ណម :　លើកទី១តាមភូមិ វគ្គ២តាមឃុំ ដល់វគ្គ៣ចូលស្រុកបានទៅអាត្រពាំងថ្មនេះយើងចូលស្រុក ហើយណា បានគេហៅចល័តស្រុក។ បើចល័តភូមិនេះ យើងលើកតាមកៀនៗភូមិនេះទៅ ដល់ចល័តឃុំគេឲ្យលើកម៉ាជួរព្រៃមាន់នេះ។

ដានី :　ចុះមឹងកាលនៅចល័តភូមិពីឆ្នាំណាដល់ឆ្នាំណា?

ណម :　ចល័តភូមិបានម៉ាឆ្នាំរួច ចូលចល័តធំត្រពាំងថ្ម។

ដានី :　កាលនៅចល័តមួយឆ្នាំនឹង មឹងគេឲ្យធ្វើការងារអីខ្លះទៅ កាលនៅចល័តភូមិ?

ណម :　អឺ! លើកភ្លឺស្រែក៏លើក ធ្វើស្រែប្រាំងក៏ធ្វើទៅ ធាក់រហាត់ទឹកថ្ងៃឡើងនាំគ្នាដកស្ទូង យប់ឡើងនាំគ្នាធាក់រហាត់ទឹកដាក់ស្រែទៅ ព្រោះជំនាន់នោះយើងមានអីមានតែ។

ដានី :　លើកភ្លឺស្រែ ធ្វើស្រែប្រាំង ធ្វើអីខ្លះកាលនឹង?

ណម :　មានប៉ុននោះឯង ដល់ពេលនេះបានគេ។

ដានី :　ចុះធ្វើស្រែវស្សាអត់ធ្វើ?

ណម :　ទេ! ស្រែវស្សាក៏ធ្វើ ប្រាំងក៏ធ្វើ ដល់ពេលនេះទៅបានគេហៅដាក់កងចល័តៗរហូត។

ដានី :　កាលនឹងនៅចល័តភូមិធ្វើការនៅកន្លែងណាខ្លះ?

ណម :　ម៉ាជួររន្ទះបាញ់។

ដានី :　រន្ទះបាញ់?

ណម : ថាទំនប់រន្ទះបាញ់ ។

ដានី : ទំនប់រន្ទះបាញ់ ក្នុងឃុំអីទៅ?

ណម : ក្នុងឃុំព្រះនេត្រព្រះនឹងហើយ បើទំនប់ភូមិនេះ តាមកៀនៗភូមិនេះទៅយើងបិទកៀនៗ អូរ ។

ដានី : ធ្វើម៉ាក្នុងភូមិយើង កាលនៅចល័តភូមិ?

ណម : ចា៎! អានោះយើងរៀងហៅកម្លាំង ។

ដានី : កាលនឹងគ្នាប៉ុន្មាននាក់ចល័តភូមិ?

ណម : អានោះកម្លាំងរួម ម៉ាភូមិតែម្ដងគេកេណ្ឌធ្វើទៅ ។

ដានី : ម៉ាភូមិគ្នាច្រើនទេ ប៉ុន្មាននាក់?

ណម : ច្រើន ហៅប្រជាជនម៉ាភូមិជាមួយវ័យកណ្ដាលជាមួយអី ។

ដានី : ចុះកាលនោះប្រធានភូមិគេអ្នកដឹកនាំ ឬក៏ប្រធានចល័តគេដឹកនាំផ្សេង?

ណម : ទេ! អានោះប្រធានភូមិនៅក្នុងភូមិបានប្រធានភូមិ ដល់ទៅនៅចល័តបានប្រធានចល័ត ។

ដានី : ប្រធានចល័តឈ្មោះអីទៅ?

ណម : អឺ! ចាំមិនបានទេ ព្រោះពួកអ្នកថ្មីគេនាំធ្វើចឹងមក វគ្គ១នារីបឿន ដុតពីនារីបឿនទៅក៏នារីស្អី ភ្លេច អឺ!ពួកនិរតីកាលនោះ រខ៊ីនៗគ្នា ។

ដានី : ចឹងបានចល័តភូមិបានម៉ាឆ្នាំ?

ណម : ចា៎! គេចេញចល័ត ។

ដានី : ពីឆ្នាំណាដល់ឆ្នាំណា មីងចាំទេ?

ណម : ពីឆ្នាំ៧៥ ៧៦ ចូលអា៧៧ក៏ចេញរហូត ។

ដានី : ចល័តឃុំឆ្នាំណាចូលចល័តឃុំ?

ណម : មកមុនដំបូងអាទៅត្រពាំងថ្ម អាមុនដំបូងគេដាក់យើងតាមឃុំៗទៅត្រពាំងថ្ម ។

ដានី : ខ្ញុំចង់សួរពីឆ្នាំ៧៥មក មុនដំបូងមីងថានៅចល័តភូមិ?

ណម : ចា៎! ៧៦ឈប់ ។

ដានី : ដល់ពេលឆ្នាំ៧៦?

ណម : នេះទំនប់រន្ទះបាញ់ គេហៅកម្លាំងទៅធ្វើ ។

ដានី : បាទ! ដល់ពេលឆ្នាំ៧៦ចូលចល័តឃុំ?

ណម : ចា៎! ឃុំទៅបានទៅនៅអាចល័តធ្វើនៅ ។

ដានី ៖ ចល័តៗឃុំព្រះនេត្រព្រះដដែល?

ណាម ៖ ចា៎!

ដានី ៖ ឃុំព្រះនេត្រព្រះ នៅកន្លែងណា?

ណាម ៖ ចល័តឃុំនេះ ធ្វើពីត្រពាំងថ្ម ពីកំបោរមករកស្រែះនេះ អាទំនប់នឹង ប៉ុនពួកខ្ញុំទីតាំងខ្ញុំមិនបាន នៅនោះទេ។ ខ្ញុំនៅចំអាម៉ាដួរខាងលិចរន្ទះបាញ់ បុកមករកស្រែះកើត នេះម៉ាវគ្គគេ រួចខាងនោះក៏។

ដានី ៖ ចល័តឃុំធ្វើការពីកំបោរ?

ណាម ៖ ចា៎! គេហៅទំនប់កំបោរមកទំនប់ស្រែះ ប៉ុន្តែពួកខ្ញុំមិនបាននៅទីតាំងខាងកើតទេ នៅខាងលិច រន្ទះ មករកស្រែះ។

ដានី ៖ ធ្វើការពីទំនប់កំបោរមកទំនប់ស្រែះ?

ណាម ៖ ចា៎! ស្រែះកើត។

ដានី ៖ ស្រែះស្អីគេ ភូមិ?

ណាម ៖ ភូមិស្រែះ វត្តស្រែះគេ។ ចល័តនៅវត្តនៅភូមិនៅវាលស្រែ។

ដានី ៖ ភូមិស្រែះក្នុងភូមិព្រះនេត្រព្រះដែរ?

ណាម ៖ ចា៎!

ដានី ៖ កាលនោះចល័តភូមិគ្នាច្រើន?

ណាម ៖ ច្រើនទាំងវ័យកណ្ដាលទាំងនារីនឹងឯង វាស់ម៉ែត្រចែកគ្នាធ្វើទៅ។

ដានី ៖ ទាំងស្រីទាំងប្រុស?

ណាម ៖ ចា៎!

ដានី ៖ កាលមីងនៅចល័តភូមិ មីងថាសុទ្ធតែចល័តនារី?

ណាម ៖ ចំរុះ ចល័តគេមិនដែលយកនារីសុទ្ធទេ ដូចថាវ័យកណ្ដាលកូនតិចក៏គេអាចយកទៅបាន ដូចថា អ្នកណាកម្លាំងក្មេងក៏គេអាចយកទៅបាន។

ដានី ៖ គ្នាច្រើនទេ កាលនៅចល័តឃុំ?

ណាម ៖ ពូអើយមនុស្សច្រើនណាស់ ប៉ុនយើងមិនមានប្រធានទៅ យើងមិនដឹងរាប់ យើងឃើញតែ មនុស្សច្រើនៗទៅ។

ដានី ៖ ពីណាគេធ្វើប្រធានកាលនៅចល័តឃុំ?

ណាម ៖ ចល័តឃុំតែពួកអ្នកពិការគេធ្វើទាហាន។

ដានី ៖ ពីណាគេឈ្មោះអី អ្នកពិការ?

ណាម ៖ អឺ! ...ងាប់អស់ហើយពួកម៉ាសេរី ពួកវាងាប់អស់ហើយ ។

ដានី ៖ បាទ! ប៉ុន្តែឈ្មោះអីទៅមីងស្គាល់?

ណាម ៖ ចល័តឃុំនៅទីតាំងនេះ តែពួកឃុំស្រុក ពួកតាហៅ តាក្រុកៗ គាត់ក្តោបក្តាប់ប្រធានឃុំ គាត់ក្តោបក្តាប់ចល័តធ្វើទំនប់ ។ កាលនោះគេហៅគណៈឃុំនេះឈ្មោះតាក្រុក ។

ដានី ៖ តាក្រុក?

ណាម ៖ ហ្នឹងហើយ ដល់ពេលអនុគណៈឃុំនោះដឹងស្អីទេមួយ ខ្ញុំភ្លេចអស់ហើយ ភ្លេចឈ្មោះបណ្តោយ ប៉ុនមិនមែនអ្នកមូលដ្ឋាននេះទេ ក្តោបក្តាប់នោះ ។

ដានី ៖ តែតាក្រុក គាត់ក្តោបក្តាប់ចល័តដែរ?

ណាម ៖ ចា៎! គាត់ចុះដាប់មើល គាត់ប្រធានឃុំហើយ គាត់ក្តាប់ចល័ត ។

ដានី ៖ ចុះឈ្មោះបឿន?

ណាម ៖ បឿននឹងផ្នែកនារី ។

ដានី ៖ បឿននឹងផ្នែកនារី?

ណាម ៖ ចា៎! បឿននឹង នារីដូចថាមាន ។

ដានី ៖ កាលនឹងធ្វើ ការនៅចល័តឃុំនឹងក៏ធ្វើស្រែដែរ?

ណាម ៖ ធ្វើស្រែៗផង ត្រូវវេណអាគេត្រូវដកលើកទំនប់ក៏ទៅៗដូចថា នៅធ្វើស្រែៗចឹងគេត្រូវការ កម្លាំងទៅត្រង់នោះផង ដកទៅ មិនទៀតទេ អត់ដែរទៅនៅត្រពាំងថ្មនោះបានទាញធ្វើទាល់ តែរួច បានគេឲ្យយើងមកនៅទីតាំង ។

ដានី ៖ ចឹងកាលនៅចល័តឃុំនឹង ធ្វើស្រែផង លើកទំនប់កំបោរ ទំនប់រន្ទះបាញ់ស្អីនឹង មីងអ្នកលើក ហើយមិនមែនទេ?

ណាម ៖ ចា៎! ចុះដាប់លើកជាមួយគេ ។

ដានី ៖ ប៉ុន្តែកាលនឹងលើកនៅនឹងទេ អត់មានទៅលើកនៅណាទេ?

ណាម ៖ ចា៎! ទៅលើកទំនប់កំបោររួចរំលងបានម៉ាឆ្នាំ បានគេនាំយើងទៅត្រពាំងថ្មៗ ដល់ទៅត្រពាំង ថ្មបាននាំកូន ។

ដានី ៖ ចុះឆ្នាំណាបានមីងទៅត្រពាំងថ្ម?

ណាម ៖ ចុះឆ្នាំ ។

ដានី ៖ មីង៧៥-៧៦មីងនៅ?

ណម ៖ ៧៦ហើយទៅត្រពាំងថ្ម មើលខ្ញុំទៅត្រពាំងថ្មបានឡើង២ឆ្នាំជាង បានស្រុក ។

ដានី ៖ ចឹងនៅចល័តឃុំបានរយៈពេលខ្វី?

ណម ៖ ខ្វីណាស់មិនសូវធំដែរ ។

ដានី ៖ ប្រហែលប៉ុន្មានខែ?

ណម ៖ អឺ! ដឹងប៉ុន្មានខែកាលនោះ គេនិយមលើកចេះ គេចាប់លើកទំនប់ ។

ដានី ៖ មីងទៅត្រពាំងថ្មនឹង ពាក់កណ្ដាលខែ ឬក៏ចុង?

ណម ៖ កំពុងតែច្រូតស្រូវ មិនដឹងខែប៉ុន្មានទេ កំពុងយើងច្រូតស្រូវវាល ក៏គេ ។

ដានី ៖ ច្រូតស្រូវប្រាំង ច្រូតស្រូវវស្សា?

ណម ៖ ហ៎! ស្រូវវស្សាយើង កាលនោះពួកខ្ញុំចុះទៅច្រូតនៅម៉ាដួរខាងកើតដូនជ្រែងក៏គេហៅកម្លាំង ទៅត្រពាំងថ្ម ក៏យើងនៅបណ្ដោយ កំពុងច្រូតស្រូវមិនទាន់រួចទេ ។ ទៅពីនោះមកទៅដឹង យើងនៅ ទៅនៅទំនប់រហូតទាល់តែឃួនចូល ។ កាលដែលឃួនចូលថ្ងៃដែលឃួនចូលនោះ ពួកខ្ញុំអង្គុយនៅនឹងព្រៃមាន់នាំគ្នាមើលឡានឃួនចូល ម៉ី(ចាស់) ៗគេរត់អស់ ។

ដានី ៖ កាលនឹងម៉េច មីងដឹងមូលហេតុអ្វីបានគេបញ្ជូនឲ្យទៅលើកទំនប់ត្រពាំងថ្ម?

ណម ៖ មិនដឹងទេ គ្រាន់តែគេថាហៅកម្លាំងទៅធ្វើទំនប់ៗ ចេះតែទៅ ។

ដានី ៖ ពីណាគេកហៅនឹង?

ណម ៖ ស្រុក គេហៅថាធ្វើចល័តតំបន់៥ ។ គេឲ្យយើងទៅធ្វើចល័តតំបន់៥ ។

ដានី ៖ ចឹងពេលដែលទៅទំនប់ត្រពាំងថ្មនឹង មីងក្នុងនាមជាចល័តស្រុក ហើយក៏ចល័តតំបន់?

ណម ៖ មុនដំបូងគេដើរចល័តឃុំៗនៅម៉ាកន្លែង ដល់ពេលគេធ្វើឡើងរួចម៉ាចប់រួចបានគេសរុបបញ្ចូល ហៅចល័តតំបន់ គេរៃបញ្ចូលក្នុង ។

ដានី ៖ ចឹងមីងទៅកន្លែងទំនប់ត្រពាំងថ្មដំបូងនៅចល័តឃុំ?

ណម ៖ ចា៎!

ដានី ៖ ចល័តឃុំនេះឃុំនោះ?

ណម ៖ ចា៎! គេដាក់ម៉ាឃុំៗ ហើយគេមិនឲ្យយើងចំរុះគ្នាទេ ដូចថាម៉ាឃុំយើងមានប៉ុន្មាន ប្រជាជនមានប៉ុន្មាននាក់ គេធ្វើឲ្យយើងនៅទៅ ។ បើប្រជាជនមិនដឹងប៉ុន្មានទេ យើងមិនដឹងសរុប បើយើងជាប្រជាជនយើងមិនដឹងទេណា គេអាចកម្លាំងច្រើនៗ ។ គេឲ្យយើងធ្វើម៉ាឃុំនេះ គេធ្វើចំនួនប៉ុន្មាន ម៉ាប្រឡោះគេឲ្យយើងធ្វើទៅ យើងធ្វើទៅ ។

ដានី ៖ បែងចែកកន្លែងនេះឃុំនេះធ្វើ កន្លែងនោះឃុំនោះធ្វើ?

ណម ៖ ចាំ! ដល់ពេលឡានទឹក គេដឹកចែកគ្រប់ឃុំ អត់មានទឹកដឹកទេ សម័យនោះ ខ្វះទឹកណាស់ ដឹកទៅគេចែកក្នុង១០០នាក់គេឲ្យយើងប៉ុន្មាន២ធុងសាំង យើងយកទៅ ។ ២ធុងសាំងនោះ ក៏យើងបែងចែកក្នុងគ្នាយើង១០០នាក់ដឹកក្នុងម៉ាថ្ងៃទៅ ដូចថាទឹកមុជមិនដែលមានទេ ខ្វះ ណាស់ទឹកមុជ ។ លក្ខណៈមាន១០ថ្ងៃដាច់ទឹក ។

ដានី ៖ ចុះមីងកាលគេបញ្ជូនទៅលើកទំនប់ត្រពាំងនឹង ដំបូងគ្នាច្រើនទេ?

ណម ៖ អូ! ច្រើនណាស់ ច្រើនមិនអាចនិយាយប្រាប់បាន មើលគ្រាន់តែគេដឹកប្រឡាយដាក់ខ្សែ ត្រៀមពីត្រពាំងថ្មមករកអាព្រៃមាន់នឹង ម៉ាខ្សែត្រៀមប៉ុននឹង ម្នាក់ម៉ាម៉ែត្រកន្ទះប៉ុននឹង ។

ដានី ៖ ចុះមីងកាលនឹងចល័តនៅឃុំព្រះនេត្រព្រះអីនឹង គេបញ្ជូនទៅទាំងអស់ ហើយក៏គេជ្រើសរើស ទៅខ្លះ?

ណម ៖ គេដូចខបមាថាគេហៅ គេត្រូវហៅ៣០-៤០នាក់ យកទៅ អឺ!លើកក្រោយ៤-១០ថ្ងៃ គេយក៥០-៦០នាក់គេចេះហៅបណ្តើរៗទៅ ។

ដានី ៖ គេមិនយកទៅទាំងអស់ម្តង?

ណម ៖ ចុះវាមានអ្នកជា វាមានអ្នកឈឺ គេដូចថាដេញអ្នកជាម៉ាសារទៅ អ្នកឈឺនោះទៀតគេដេញ ទៅទៀតណា គេហៅដឹងគេប្រមូលកម្លាំង ច្រើនវគ្គណាស់ ។ ប៉ុនយើងទៅនៅនោះគេដូចថាទី តាំងគេម៉ាឃុំចឹងទៅ ប្រធានឃុំគេឈ្មោះតាស្មៀន គេអ្នកគ្រប់គ្រងយើងទាំងអស់ រួចបានគេ បែកកន្លែង ។

ដានី ៖ ចុះមីងកាលមីងទៅឆ្នាំ៧៦ដំបូង គេចាប់ផ្តើមគេមានធ្វើពីមុនមកហើយខ្លះហើយ?

ណម ៖ អត់មានទេ ។

ដានី ៖ អត់មាន?

ណម ៖ អត់មាន ។

ដានី ៖ មីងចាប់ផ្តើមដំបូងបង្អស់ អាកន្លែងទំនប់នឹង?

ណម ៖ ចាំ! ទៅដល់គឺវាលស្រែសុទ្ធសាធ ។

ដានី ៖ វាលស្រែសុទ្ធសាធឆ្នាំ៧៦?

ណម ៖ ចាំ! វាលស្រែនៅអែបនោកន្លែងតាវ៉ាំងនោះ វាមានព្រៃរបោះ បើចាប់អាពីកន្លែងស្ពឺគេហៅ ដើមពោធិ៍ ស្ពានរាបទៅរកអាត្រពាំងថ្ម មានដើមពោធិ៍២ត្រពាំងនឹងគេហៅស្ពានរាប ។ គេធ្វើកាត់ដើមពោធិ៍២ម្ខាងលិចមួយ ខាងកើតមួយ គេកាត់ដើមពោធិ៍ចោលកន្លែងនោះវាល

ទៅដល់ត្រពាំងថ្មខាងជើង ។ បើចាប់ពីត្រឹមស្ពានរាបមករកកន្លែងតាវ៉ាំងនេះ វាមានដុបកំដេក កំដុប មានព្រៃឈើ ហើយដើមឈើធំៗ ។ រួចចាប់ពីត្រឹមត្រពាំងថ្មទៅត្រឹម គេហៅភូមិពត្រ ដល់ទៅស្វាយទៀតទេ អែបទៅកូនខ្វែង ខ្ញុំមិនស្គាល់ដែរ អានឹងបានវាលស្រែដែរ ។ រួចចាប់ពី ជើងទៅរកអាកូនខ្វែងនោះ វាលស្រែរហូតមកសព្វថ្ងៃដែលគេធ្វើស្រូវ ។

ដានី : ចឹងមីងទៅដំបូងអត់មានអីទាំងអស់ សុទ្ធតែវាលស្រែទេ?

ណម : អត់មានទេ ពួកខ្ញុំទីតាំងមុនគេដំបូងបង្អស់ មិនទាន់មានអ្នកណាចាប់លើកអីទេ ឡើងខ្ញុំទៅភ្លល់ មិនដឹងគេឲ្យទៅធ្វើអី គេប្រាប់ថាលើកទំនប់ គេថាយើងនៅទីតាំង ។ ទាល់តែគេគូររៀងទំនប់ ខ្ពស់ ។

ដានី : គេគូរ?

ណម : ចុះគេចងខ្សែបង្គោល គេបោះឲ្យយើងមើល ធ្វើដូចរៀងតារាងបាល់ ។

ដានី : ប៉ុន្តែពេលដែលមីងទៅដំបូង គេមានបោះបង្គោលបោះអី?

ណម : បោះហើយ គេបោះរួចគេចង់ខ្សែឲ្យយើងមើលតារាងរួមខ្ពង់ប៉ុន្មានទទឹងប៉ុន្មាន ដល់ពួកភ្លល់ មិនដឹងគេធ្វើអី ។

ដានី : ចុះគេបោះហើយ គេប្រាប់ថាទទឹងប៉ុន្មានទៅ?

ណម : កាលនោះ គេធ្វើទទឹងធំណាស់ ប៉ុនមិនដឹងប៉ុន្មានម៉ែត្រទេ ឃើញតែទទឹកគេមិនហ៊ានសួរ ។

ដានី : ចុះកំពស់?

ណម : កំពស់ត្រឹមនោះឯង ។

ដានី : ខ្ពង់ប៉ុន្មានទៅ?

ណម : ដឹងប៉ុន្មានម៉ែត្រ ពួកខ្ញុំមិនដែលហ៊ានសួរគេ ។

ដានី : កំពស់ប៉ុន្មាន?

ណម : កំពស់ទំនប់ ។

ដានី : កំពស់ណាទៅ ទំនប់?

ណម : សព្វថ្ងៃនេះ រៀបទំនប់ប៉ុន្មានម៉ែត្រ កំពស់គ្រាន់ដែលតែឃើញគួរតែខ្លាច ។

ដានី : គ្រាន់នឹងប្រហែលមីងស្មានប៉ុន្មានម៉ែត្រ?

ណម : មិនចេះស្មានទៅអើតមើលដូចចុងដូង គេចងឲ្យ ។

ដានី : ដូចកំពស់ចុងដូង?

ណាម ៖ អឺ! មើលទៅមិនឃើញទេ ។

ដានី ៖ ចុះមីងទំនប់ដែលមីងទៅដឹបូង មីងថាវាលស្រែស្ងួត កាលនឹងវាលស្រែស្ងួតអត់មានអីទាំងអស់ យើងគ្រាន់តែបោះបង្គោលឲ្យយើងមើលទីតាំង?

ណាម ៖ ចាក់វែកចាក់ ។

ដានី ៖ ចឹងមីងពេលនឹង មីងដឹងថា ពេលដែលទៅដល់ដំបូងក្នុងដែលគេចាត់ឲ្យលើកនឹង ទីតាំងទំនប់នឹងនៅក្នុងចន្លោះពីកន្លែងណាដល់កន្លែងណាទៅ?

ណាម ៖ ខ្ញុំចាប់ផ្ដើពីត្រឹមលិចរហូតដល់ត្រពាំងថ្ម ប៉ុនដូចថាឃុំយើងធ្វើរួចចេះទៅ ឃុំណាមិនទាន់រួច យើងទៅជួយ រួចហើយឆាប់បន្តៗរហូតទៅ គេថាឃុំយើងមុនគេចេះរួចបានមុនគេ ឃុំខាងនោះមិនទាន់រួច យើងបន្តទៅជួយបំពេញ ចេះតែតៗទៅទាល់តែរួចទាល់តែទៅដល់ជុំត្រពាំងភូមិត្រពាំងថ្មរួចបានកាច់ទៅដើងណា ។

ដានី ៖ ចុះមីងបើតាមមីងដឹង ដូចថាទំនប់នឹងចាប់ផ្ដើមពីភូមិណា ហើយដើមទំនប់ពីភូមិណា ចុងទំនប់ដល់ភូមិណា?

ណាម ៖ ចុះនៅអែបតាវ៉ូង ឃើញប្រឡាយទឹកគេ ។

ដានី ៖ ដំបូងពីកន្លែងដើមទំនប់គេហៅអីគេ?

ណាម ៖ ខាងកើតភូមិតាវ៉ូង ។

ដានី ៖ ខាងកើតភូមិតាវ៉ូង ហើយដល់ពេល?

ណាម ៖ ពួកខ្ញុំចាប់ផ្ដើពីត្រឹមអាប្រឡាយជីកធ្លាក់តាវ៉ូងនេះ ។

ដានី ៖ ភូមិតាវ៉ូង?

ណាម ៖ ចា៎! ជ្រុងវាមិនដល់ភូមិតាវ៉ូងទេ ចុងប្រឡាយនឹង មានអាប្រឡាយធ្លាក់ទៅច្រកត្បូងភូមិតាសុក អាប្រឡាយក្លោះទៅចេះ អានេះធ្វើក្រោយ ។

ដានី ៖ ភូមិតាវ៉ូងនៅក្នុងឃុំអីទៅ?

ណាម ៖ នៅក្នុងឃុំស្ពឺទេ ។

ដានី ៖ ស្រុកអីគេ?

ណាម ៖ ស្រុកភ្នំស្រុក ។

ដានី ៖ ភ្នំស្រុកពីភូមិតាវ៉ូង អានឹងដើមប្រឡាយ ចុងប្រឡាយ?

ណាម ៖ ចា៎! វាមិនមានទៅដល់តាវ៉ូងឯណា ជុំប្រឡាយក្លោះធ្លាក់ទៅចេះ រួចនេះទំនប់វានៅ ដូចថាតាវ៉ូងវានៅលិច ខ្ញុំចាប់ផ្ដើពីត្រឹម-ក ទៅនេះ ។

ដានី ៖ ហើយទៅចប់តែត្រង់ណា?

ណម ៖ រហូតទៅដល់អាភូមិត្រពាំងថ្ម ប៉ុនចល័តពួកខ្ញុំដូចថាគេដាក់ម៉ាកង១ ម៉ាឃុំ១ ដល់ឃុំខ្ញុំរួចមុនទៅជួយឃុំគេធ្វើម៉េចឲ្យរួចបណ្តោញគ្នា ។

ដានី ៖ ចំងាយប៉ុន្មានគីឡូទៅ ពីជិតភូមិតារ៉ូងរហូតដល់ត្រពាំងថ្ម?

ណម ៖ អត់ដឹង ។

ដានី ៖ ឆ្ងាយទេ?

ណម ៖ ឆ្ងាយដែរ ជិត៥-៦គីឡូដឹង ។

ដានី ៖ ៥-៦គីឡូ?

ណម ៖ ពូតែគេថា៥-៦ ៗ ថាតែតាមគេទៅ មិនទៅសួរគេ ព្រោះជុំនោះឯង ដល់ពួកខ្ញុំធ្វើទៅដេញទៅៗដល់ភូមិគេស្រុកស្រែមិនទាន់រួចក៏ជួយគ្នាទៅ ដូចថាស្រុកណាមិនទាន់រួច យើងចេះជួយបណ្តោញៗរហូតដល់ជប់នឹង ។ បានគេវាស់កម្ចាំងតទៅដើងទៀត ដល់ពេលម៉ាដើងទៀត ខ្ញុំលើកទី៣ ខ្ញុំបានទៅដល់ភូមិពង្រ ។

ដានី ៖ ចុះមីងអត់ដឹងទេទទឹងវាប៉ុន្មាន កំពស់ប៉ុន្មាន ខ្នងទំនប់ប៉ុន្មាន?

ណម ៖ អត់ដឹងទេ អត់ដែលហ៊ានសួរគេទេ គេគ្រាន់ថានេះលេខ វាស់ឲ្យក្រុមនេះដូចថាយើងម៉ាក្រុមគេឲ្យវាស់ដូចថា១០នាក់នេះគេវាស់ឲ្យទៅ ចំនួនប៉ុន្មានដែលយើងត្រូវលើកចំនួន៣គីប ទទឹង១ម៉ែត្រចេះ បណ្តោយ៣ម៉ែត្រនេះគេបោះបង្គោលឲ្យយើងម្នាក់ យើងក៏ចាប់ម៉ាក្រុមយើងទៅ១០នាក់ ។

ដានី ៖ ចុះមីងក្រុមមីងដំបូងនៅកន្លែងណា ដែលមីងទៅដល់ដំបូង?

ណម ៖ ខ្ញុំនៅអែបតារ៉ូង ។

ដានី ៖ អែបតារ៉ូង?

ណម ៖ ចាំ! នៅកើតតារ៉ូង ប៉ុនខ្ញុំនៅវាលឫស្សី ។

ដានី ៖ ដល់ពេលកាលនឹងគ្នាមីងប៉ុន្មាននាក់?

ណម ៖ ម៉ាឃុំព្រះនេត្រព្រះ គេយកទៅដាក់ ។

ដានី ៖ ម៉ាឃុំព្រះនេត្រព្រះ គ្នាប៉ុន្មាននាក់កាលនឹងគេយកទៅដាក់?

ណម ៖ ដឹងប៉ុន្មានរយនាក់ទេ ច្រើនដែរ ។

ដានី ៖ ពីណាគេអ្នកធ្វើប្រធាន?

ណម ៖ កាលនោះតាស្មិន ប្រធាន គេហៅប្រធានសហករណ៍រួម ។

ដានី ៖ ប្រធានសហករណ៍រួម ឈ្មោះតាស៊ិន?

ណម ៖ ចា៎! គេហៅ គាត់ទៅក្រុមជំនុំម៉ាឃុំតែម្តង ឈ្មោះតាស៊ិន តែម្នាក់ទេ គាត់ហៅទៅគ្រប់គ្រងណា គាត់បញ្ជា ។ ប៉ុនសម័យនោះ វាពិបាកគ្នាច្រើន ។

ដានី ៖ កាលនោះគេបែងចែកកម្លាំងអីយ៉ាងម៉េចខ្លះ?

ណម ៖ បែកដូចថាទៅដល់កម្លាំងណារៀងខ្សោយ ទៅគេដាក់ក្រុមគេហៅកម្លាំងទី២ទៅ ។

ដានី ៖ កម្លាំងទី២?

ណម ៖ ហ្នឹង ដូចថាយើងរៀងគ្រាន់គេដាក់កម្លាំងទី១ ៗដីងតែម្នាក់៣ម៉ែត្រគីបហើយ ។

ដានី ៖ កម្លាំងទី១ម្នាក់ ៣ម៉ែត្រគីប?

ណម ៖ ចា៎!

ដានី ៖ ចុះកម្លាំងទី២?

ណម ៖ ខ្លះទៅក៏២ម៉ែត្រគីប ម៉ាម៉ែត្រគីបដាងក៏មាន ។

ដានី ៖ គេមើលម៉េច អ្នកកម្លាំងទី១ កម្លាំងទី២?

ណម ៖ គេជ្រើសរើសយកមាឌៗណារៀងខ្សោយតិចគេដាក់កម្លាំងទី២ទៅ យើងដូចថាយើងតំរៀបចេះទៅគេមើលយើង គេដកចេញមួយៗទៅណា ។ រួចបានគេយកយើងបញ្ចូលជាមួយអ្នកគេមិនថាក្រុមនេះទាំងអស់អត់ទេ ដូចថាមើលទៅមនុស្សរៀងមាឌស្ទើរតិច គេដកផ្សេងទៅសូម្បីតែយប់ក៏គេមិនអនុគ្រោះដែរ ។ អ្នកងងឹតភ្នែកអង្គុយតំរៀបដូរទៅ ។

ដានី ៖ ចុះមីងនៅក្នុងកម្លាំងទី១?

ណម ៖ ចា៎! ខ្ញុំកម្លាំងទី១ ។

ដានី ៖ ចុះអ្នកដែលពីឃុំព្រះនេត្រព្រះទៅនឹង ពីឃុំព្រះនេត្រព្រះទៅនឹង កម្លាំងទី១ហើយនឹងកម្លាំងទី ២នឹង កម្លាំងណាច្រើនជាង?

ណម ៖ កម្លាំងបែងចែក សឹងថាស្មើភេទគ្នា គេចំរាញ់យកអាទី២មានប៉ុន្មានរយ ទី១មានប៉ុន្មានរយគេដាក់យកតែ២នាក់នោះឯង ។

ដានី ៖ ប៉ុន្តែកម្លាំងទី១ច្រើនជាងទី២ ឬទី២ច្រើនជាងទី១?

ណម ៖ ភាគច្រើនគេយកអាទី២នេះឯង ដើម្បីឲ្យជឿនលឿនរបស់គេ ។

ដានី ៖ ចឹងកម្លាំងទី១ ៣ម៉ែត្រគីប កម្លាំងទី២?

ណម ៖ ២ម៉ែត្រគីបក៏មាន អីខ្លះលើកមិនរួច យប់ឡើងលើកបង្ហើយទៅ ។ បើអ្នកណាគេលើករួចយប់ឡើងគេបានដេកតិចទៅ ។

ដានី : ៣ម៉ែត្រគីបនឹង បានន័យថាយើងជីករណ្ដៅ?

ណម : ជំរៅម៉ាម៉ែត្រ កំពស់ម៉ាម៉ែត្រ ទទឹងម៉ាម៉ែត្រ បណ្ដោយម៉ាម៉ែត្រ ។ ក្នុងម៉ាម៉ែត្រគីបនោះគេ វ៉ៃម៉ាម៉ែត្រ៤ជ្រុងទាំងជំរៅ ទាំងកំពស់ យកអាចម៍ដីឲ្យអស់ ។

ដានី : អាចម៍ដីអស់?

ណម : ចាំ!

ដានី : អានឹងម៉ាម៉ែត្រគីប?

ណម : ចាំ!

ដានី : ចឹងមីងត្រូវយកអាចម៍ដីអស់៣ម៉ែត្រគីប?

ណម : ចាំ! ៣ម៉ែត្រគីបគេវាស់មើលទៅ ។

ដានី : ចឹងយើងលើកពី ជីកពីរណ្ដៅនឹងទៅកន្លែងទំនប់ចំងាយប៉ុន្មាន?

ណម : អូ! ខ្ពស់ទៅ ឆ្ងាយទៅ គេមិនដែលឲ្យជីកជិតៗទេ ចំងាយពីជើងទំនប់យ៉ាងទាប ។

ដានី : ចុះមីងមិញថាយើងលើ ឧបមាថាណ្ដៅជីកហើយនឹងមកកន្លែងទំនប់ចំងាយប៉ុន្មាន?

ណម : ១០ម៉ែត្រជាងយ៉ាងតូច អត់ដែលចាក់គឺបទេ គេឲ្យជីកឆ្ងាយពីជើងទំនប់១០ម៉ែត្រ ។

ដានី : ពីជើងទំនប់១០ម៉ែត្រយើងរែកមក?

ណម : ហ្នឹងហើយយើងជីកពីខាងនេះរួច រែកទៅចាក់ ។ ប៉ុនកន្លែងដែលជីក គេមិនដែលជីកទំនប់នេះ វាលទេ យ៉ាងជ្រៅម៉ាម៉ែត្រជីកយកអាចម៍ដីខាងក្នុងទៅចាក់ទំនប់ ខាងក្រៅគេអត់ឲ្យជីកទេ ឲ្យជីកតែក្នុងអាង អាក្បែរខាងជើងអាង រួចយកដីទៅចាក់លើ ។ ដូចថាខាងត្បូងនោះគេមិន ឲ្យជីកទេ ក្រៅពីមិនឲ្យជីកទេ យកដីពីនេះឲ្យជីខាងនេះជ្រៅយកទៅចាក់នោះ ។

ដានី : បានន័យថាជីកប្រហោះប៉ុននឹង លើកប៉ុននឹងទៅ កន្លែងនេះប្រហោះៗ?

ណម : ចាំ! ប្រហោះជីកឡើងស្មើរហូតដល់ចែកជុំវិញនឹង ។

ដានី : ចុះមីង៣ម៉ែត្រគីប យើងជីកចាប់ផ្ដើការម៉ោងប៉ុន្មាន?

ណម : អឺ! ដែលតិច ព្រោះគេវាស់ឲ្យយើងរួច ជួនកាលយើងក្រោកពីម៉ោង៤ទៅ បានម៉ោង៤ ម៉ោង៣អីក៏មាន ជួនកាលម៉ោង៥-៦យប់មិនទាន់រួចសល់កន្លះគីប យើងមកបន្ថែយយប់ ទៀតទៅ គេធ្វើម៉េចក្នុងម៉ាថ្ងៃនឹងឲ្យយើងធ្វើឲ្យរួច ។ ឧបមាថាខ្ញុំរួចទៅជួយទៅ ប្អូនលំបាក ប្អូនជួយតែគ្នាយើងនិយាយចេះទៅ ទាំងអស់គ្នា ដូចថាក្នុង១០នាក់ម្នាក់នឹងខ្សោយអន់ជាង គេក៏យើងជួយម្នាក់នឹងឲ្យរួចទៅ បានយើងអាចបានសម្រាកបាន យើងសម្រាកតិចទៅ ។

ដានី : ចឹងចាប់ផ្ដើមធ្វើការតាំងពីម៉ោង?

ណម : ម៉ោង៤ព្រឹក ។

ដានី : ដល់ពេលសម្រាកពេលថ្ងៃម៉ោងប៉ុន្មាន?

ណម : សម្រាកៗក៏ម៉ោង១២ ម៉ោង១ចុះ ។ ប៉ុន្តែបើយើងម៉េចហ៊ានសម្រាក ខ្លាចអត់រួច ច្បាប់គេសម្រាកចឹងឯងហើយដូចថាយើងទៅ ម៉ោង៤ចេះ ម៉ោង៧គេឲ្យស៊ីបបរម្ដង ។ បាយគេឲ្យយើងស៊ីថ្ងៃ ។

ដានី : ពេលព្រឹកគេឲ្យហូប?

ណម : ឲ្យស៊ីបបរ ។

ដានី : បបរម៉ោង៧ព្រឹក?

ណម : ចា៎! ដូចថាយើងទៅម៉ោង៤ចេះ ម៉ោង៧គេហៅយើងឲ្យស៊ីបបរ ដល់យើងស៊ីបបររួចយើងចុះទៀតហើយ ដល់ម៉ោង១១គេឲ្យយើងស៊ីបាយហើយ ។ បើថាយើងមិនទាន់រួច គេចាំម៉ោង១២ ក្រុបបាយឲ្យយើងស៊ី ។ អាពាក្យថាម៉ោង១ចុះ វាមិនដែលបានស៊ីម៉ោង១ទេ ។

ដានី : ចឹងដល់ម៉ោង១១នឹង ហូបបាយ?

ណម : ចា៎!

ដានី : ដល់ពេលម៉ោង២ចុះ?

ណម : ម៉ោង១ ប៉ុនអត់ដែលឈប់ទេ ស៊ីតែបាយរួចធ្វើទៀតទៅ ព្រោះយើងខ្លាចអត់រួច ។ ដល់កំណត់គេឧបមាថាមាន ខាងលើគេមកមើលណា ខ្ញុំធ្វើខុសម្ដង ដល់គេទៅមើល ខ្ញុំបង់រ៉នអីនាំលេង វានេះឃឹត ខ្ញុំ បង់រ៉ន លឿន ដួយវាអត់ហ៊ានឈប់ កាលនោះគេចុះទៅមើល គេភ្ជង់ប្រុងបាញ់ខ្ញុំណា៎ ។

ដានី : គេថាម៉េច?

ណម : គេថាខ្ញុំធ្វើការខុសម៉ោង ។ ចុះពីលើឡាន យកកាំភ្លើងភ្ជង់ចុង...(ស្ដាប់មិនបាន) ដកកាំភ្លើងខ្លីប្រុងដកពីចង្កេះប្រុងបាញ់ខ្ញុំ ។ សួរថាមិត្តឯងនៅកូនចៅអ្នកណា ខ្ញុំប្រាប់ថាប្រធានខ្ញុំ គាស្មិនគេទើបមក ។ មិត្តយើងមិនដឹងម៉ោង ព្រោះអត់មាននាឡិកាពាក់ ។ ពេលដែលអ្នកធំចុះទៅគេឲ្យយើងសម្រាកឲ្យទៀងទាត់ ឲ្យគេមើលណា កុំឲ្យយើងធ្វើខុសម៉ោង ដល់យើងមិនដឹងថាគេទៅ ។

ដានី : ចឹងគេលាក់ការណ៍ដែរ គេខ្លាច?

ណម ៖ អូ! លាក់ការណ៍មហាលាក់ការណ៍ហើយ គេប្រុងបាញ់ខ្ញុំចោលកាលនោះ ខ្ញុំជួយវាឯង ដល់វាអត់ទាន់រួច ខ្ញុំខ្លាចអត់រួចល្ងាចក៏នាំគ្នាជួយ ។ គ្នាយើងម៉ាក្រុមយើងចេះតែជួយគ្នាទៅៗ គេប្រុងបាញ់ខ្ញុំចោល ។ ថាជីវិតខ្ញុំថ្ងៃ កាលនោះបើសិនជាវាកាស់កែ ខ្ញុំក៏ងាប់ទៅ ។

ដានី ៖ ពីណា កាលណា អ្នកទៅមើលនឹង?

ណម ៖ គណៈស្រុកឈ្មោះតាវ៉ាល់ ។

ដានី ៖ តាវ៉ាល់?

ណម ៖ ចាំ! តាវ៉ាល់ តាមោង បងប្អូនគេ ។

ដានី ៖ តាវ៉ាល់ តាមោង ធ្វើអីគេ?

ណម ៖ គណៈស្រុកដែលគេគ្រប់គ្រងតំបន់ ចល័តតំបន់៥ គេថៅហ្វាយស្រុកហើយ គេគ្រប់គ្រងចល័តតំបន់៥ទៀត ចង់កាំភ្លើងភ្ជង់ខ្ញុំទៀត កន្លែងស្ពានរាប ។ ខ្ញុំក៏មិនដឹងនិយាយថាម៉េចដែរ គ្រាន់គាត់ចុះពីលើកន្លាន ថាបាញ់មិត្តឯងចោលមួយ ធ្វើការខុសម៉ោង ។ ដល់ពេលគាត់សួរថាឯណាប្រធានមិត្តឯង គាត់ប្រធាននោះ គាត់ស្រឡាញ់ខ្ញុំដែរ និយាយឲ្យត្រង់ គាត់ស្រឡាញ់ដូចថាខ្ញុំទៅនៅ ខ្ញុំមិនដែលទៅឈប់ទេរឿងការងារ មិនដែលចេះពុតថាឈឺទេ ។

ដានី ៖ ចឹងពេលដែលឈ្មោះតា?

ណម ៖ តាវ៉ាល់ប្រធានធំ តាមោងអនុប្រធាន បងប្អូនគេ ។

ដានី ៖ តាវ៉ាល់ តាមោង?

ណម ៖ ថៅហ្វាយស្រុកនេះឯង ។

ដានី ៖ ថៅហ្វាយស្រុកណា?

ណម ៖ ថៅហ្វាយស្រុកព្រះនេត្រព្រះ ។

ដានី ៖ ចឹង តាវ៉ាល់ តាមោង ថៅហ្វាយស្រុកព្រះនេត្រព្រះ?

ណម ៖ ចាំ! គ្រោងម៉ាព្រះនេត្រព្រះ ហើយគាត់ក្តាប់ម៉ាតំបន់៥ចល័ត ។

ដានី ៖ កាលនឹងអ្នកភ្ជង់ពីណា?

ណម ៖ តាវ៉ាល់ ភ្ជង់កាំភ្លើងខ្ញុំ កាំភ្លើងកន្លែងតាវ៉ាល់ ប៉ុន្មានសារដែរ ប៉ុនយើងមិនហ៊ាននិយាយនឹកឃើញលើកទំនប់ថ្មីៗ ។ ប៉ុនយើងឈឺចាប់ប៉ុនណា យើងធ្វើគេមិនកើត មកគេចាប់មនុស្សចោលដាក់មុខយើងក៏យើងមិនហ៊ានចេះឯង អាដេកនៅជុំគ្នាយប់ឡើង ។

ដានី ៖ ចឹងគេឲ្យចុះធ្វើការពីម៉ោង១ រហូតដល់ម៉ោងប៉ុន្មានបានឈប់?

ណាម ៖ ក្នុងច្បាប់គេ ម៉ោង១ដល់ម៉ោង៤ ការពិតយើងមិនរួចក៏គ្មានបានឈប់ដែរ យប់ឡើងសូម្បីតែងងឹតមាន់ទៅអង្គុយតំរៀបជួរហូចទៅ អ្នកដែលភ្ញីក៏ ហើយដែលមានអំពូលម៉ែត្រមានអី ។

ដានី ៖ ចឹងម៉ាថ្ងៃ ដល់ពេលម៉ោងប៉ុន្មានហូបបាយល្ងាច?

ណាម ៖ ម៉ោង៥គេឲ្យយើងហូបហើយ ។ ហូបរួច បើយើងមិនទាន់រួចយើងទៅទៀតទៅ បើយើងរួចហើយបានសម្រាកទៅ ម៉ោង៨ក៏ទៅៗ ។

ដានី ៖ ហូបបាយគ្រប់គ្រាន់ទេកាលនឹង?

ណាម ៖ បាយវាមិនអត់ទេ វាអត់តែម្ហូប បើនិយាយធំបំផុតខ្វត់រឿងទឹក ខ្ញុំនិយាយមិននេះទេ ជីវភាពសូម្បីតែឡានខូចនៅវាលស្រែ រត់ទៅវាមិនឲ្យយើងជីកផង ។ វាសុខចិត្តបាញ់កាំភ្លើងឲ្យយើងចេញមកវិញ វាបង្ហូរទឹកចោល យកឡានផ្សេងអូសឡាននេះទៅធ្វើទៅ មិនធម្មតា ។

ដានី ៖ ចុះបាយ កាលនឹងហូបម៉ាឆ្អែត ក៏គេចែករបប?

ណាម ៖ ចែករបបក៏យើងហូបមិនអស់ដែរ គេរបបម្នាក់ម៉ាចាន ។

ដានី ៖ ម៉ាចានប៉ុនណា?

ណាម ៖ អាចានដូចវៀងផ្តិល ។

ដានី ៖ ធំ ចានធំ?

ណាម ៖ ប៉ុននេះដាក់ទៅ ខ្ញុំស៊ីមិនដែលអស់ទេ ខ្ញុំមិនដែលយកអស់ ។ បើអ្នកណាគេស៊ី បើប្រុសៗគ្នាស៊ីជួនកាល គ្មានថែមទេ មើលចុងភៅដូចថាស្គាល់គ្នាធ្វើចេះឯង ដូចថាចុងភៅធ្វើការយល់គ្នា ទៅណា ដាំ...(ស្តាប់មិនបាន)ទុកឲ្យប្រុសៗ ។ បើខ្ញុំស៊ីមិនដែលអស់ទេ ។

ដានី ៖ ចឹងគេឲ្យ៣ពេល ដំបូង?

ណាម ៖ ៣រហូត ។

ដានី ៖ ចុះម្ហូន ហូបជាមួយអី?

ណាម ៖ ហូបមិនមានទេ ជួនណាទៅមានកម្មវិធីជីកទៅឲ្យស៊ីទៅ ដូចត្រីងៀត ភាគច្រើនតែប្រហុកបើនិយាយ ប្រហុកចំហុយច្រើន ។ ដូចថាយូរៗទៅម៉ាខែ ឬកន្លះខែ មានគេវៃជីកសាច់គោទៅឲ្យ យើងស៊ីម្តងក៏មាន តែយើងចែកគ្នាទៅ បើយើងដូចថាជំនាន់នោះ ម៉ាចានប៉ុននេះ ក៏យើងស៊ីជុំគ្នា១០នាក់ ស៊ីស្មើគ្នាល្អណាស់ ។ ដូចថាមិនមានអ្នកណាស៊ីច្រើនជាងអ្នកណា ។ គិតថាអត់...(ស្តាប់មិនបាន) ម៉ាកំប៉ុង ក៏យើងអាចចែកគ្នា១០នាក់ជីកបានដែរ ។ មានណាអាកំប៉ុងរមួលគេវាស់កំពស់ប្រវែងនេះឯងកំប៉ុងហើយវាមូលកង់ៗចេះ ដូចថាម៉ាពេលនោះ

១០នាក់ក៏ឲ្យកំសៀងនោះ២លីត្រនោះ ដែលទឹកវារៀង...(ស្តាប់មិនបាន) ស្បៀយ គេឲ្យយើងដឹកក្នុង១០នាក់នោះគេឲ្យម៉ាកំសៀវទេ ស៊ីបាយម្តង យើងចេះតែចែកគ្នាម៉ាលីត្រ ២លីត្រ ដល់ទឹកនោះមិនអស់ យើងបណ្តើរចែកទៀតទៅ ដឹកម្នាក់ម៉ាលីត្រៗ ដូចថាទឹកសល់ ចែកគ្នាសារថ្មីវិញទៅណា ។ នេះរបបថាធំបំផុតរឿងទឹកខ្វះ មែនទែន ដល់យើងស៊ូទ្រាំមិន បាន យើងត្រូវគ្នាដូចថាយុវជនយុវនារីយើងដើរ មើលព្រឹកឡើងដំបូកណាដែលមាន ជាតិ ទឹកសន្សើម យើងនាំគ្នាទៅជីកទៅ ជំរៅបាន៣-៤ម៉ែត្រ ម៉ាយប់បានម៉ាថាំង២ថាំង យើង ចែកគ្នាលាបខ្លួនទៅណា ។ នៅនោះនាំគ្នាជីកអណ្តូងថ្ងៃៗ ថ្ងៃឡើងទៅជីកទៅ ស្រីចេះជួយរួម គ្នាទៅ ដូចថាម៉ាយប់ក៏យើងបាន២ថាំង ៣ថាំងចេញ ដងមកជ្រលក់កន្សែងជូតខ្លួនទៅ ។

ដានី ៖ អត់មានទឹកមុជ?

ណាម ៖ អូ! ទៅនៅនោះ អត់ដែលមានទឹកមុជទេ អាស្ពានរាបគេហៅស្ពានរាបនោះ ខះអស់ ។

ដានី ៖ ចុះមីងម៉ាអាទិត្យយើងធ្វើការរាល់ថ្ងៃអត់មានឈប់ថ្ងៃសៅរ៍ អាទិត្យទេ?

ណាម ៖ អត់មានទេ បើថាអ្នកណាខ្ជិល ក៏ខ្លួនឈឺឈប់ដែរ ដូចខ្ញុំមិនឈឺ ខ្ញុំមិនដែលចេះកុហកគេថាឈឺ ។

ដានី ៖ ចឹងយើងធ្វើការកាលជំនាន់នឹង ពួកមីងមានសុទ្ធតែប្រជាជនចាស់ ប្រជាជនថ្មីទៅធ្វើការលាយគ្នា ឬក៏អត់ទេ?

ណាម ៖ លាយៗ ដេកនៅជុំគ្នា ។

ដានី ៖ អ្នកនៅមកពីភ្នំពេញ?

ណាម ៖ ចា៎! មានទៅប្រកាន់ យើងស្រឡាញ់គ្នាទៅ ដូចថាអ្នកភ្នំពេញយើងជួយគ្នា នឹកឃើញថា បើ ក្រុមគេមិនដឹង បើក្រុមខ្ញុំនៅជុំខ្ញុំស្រឡាញ់គ្នាទាំងអស់ គេចាត់ឲ្យម៉ាក្រុមៗ គេវាស់ឲ្យទទឹង១០ ម៉ែត្រៗ យើងចាប់ម៉ាគ្នាយើងម៉ាក្រុម ។

ដានី ៖ ចុះកាលនឹងមានច្បាប់មកលេងផ្ទះ?

ណាម ៖ អូ! អត់មានទេ ខ្ញុំកាលនឹងមកលេងផ្ទះម្តងគេមកចងយកទៅវិញ ។

ដានី ៖ ពីណា មីង?

ណាម ៖ កាលនោះប្រធាននោះគេឲ្យខ្ញុំមកៗទៅគេ ។

ដានី ៖ ពីណាគេ ប្រធានណាឲ្យមក?

ណាម ៖ កាលនោះប្រធាន អានោះឥឡូវងាប់ហើយ ។

ដានី :	ឈ្មោះអី?

ណាម :	ភ្លេចឈ្មោះ ក្មេង ដូចថាយើងនៅផ្ទះគេឲ្យមក២ថ្ងៃ យើងមកតែម៉ាថ្ងៃ ក៏ ។

ដានី :	ប្រធានអីគេអ្នកឲ្យមីងមក?

ណាម :	ប្រធានក្ដោបក្ដាប់យើងបន្ដមកទៀត ។

ដានី :	ក្ដោបក្ដាប់ពីត្រឹមណាមក?

ណាម :	កម្លាំងនោះគេហៅប្រធានកងធំ គេក្ដាប់យើង១០០នាក់ ទៅគេឲ្យយើងមក២ថ្ងៃ ទៅយើង យើងម៉ាលើសតែម៉ាថ្ងៃ គេចងយកយើងទៅវិញ គំរាមយើង ខ្លាចគេ ។

ដានី :	កាលនឹងឆ្នាំណា ដែលគេឲ្យមក?

ណាម :	ឆ្នាំនឹងលើកទំនប់ត្រពាំងថ្មរួច ខ្ញុំសុំមកផ្ទះបាន២យប់ ខ្ញុំមកនៅឡើង៣យប់ ក៏គាត់មកចាប់ ។ ឈ្មោះអាចក ដែលមកចាប់ខ្ញុំ ។

ដានី :	ឈ្មោះចក ប្រធានកងធំនឹង?

ណាម :	ទេ! ប្រធានកងធំឈ្មោះ អាលឿង ។

ដានី :	ឈ្មោះ លឿង?

ណាម :	អានេះ គេហៅអាពួក ។

ដានី :	ប្រធានកងធំឈ្មោះអី?

ណាម :	ឈ្មោះអាប៊ុពួកៗ ដល់កូនចៅគេឈ្មោះអាចក់ៗ គេចងខ្ញុំ ។

ដានី :	ប៊ុ ពួក?

ណាម :	តាលិងៗ មកនៅចល័តគេហៅអាចារ្យភូមិ កម្លាំងប៉ុន្មានរយនាក់ទេ ។

ដានី :	អូ! ចឹងប្រធានកងធំ មកលេងផ្ទះ កាលនឹងមកនៅគ៣ដើមហើយ?

ណាម :	ចា៎! ខ្ញុំទៅបែកចេញពីត្រពាំងថ្មហើយ ។

ដានី :	មកចងមីងយ៉ាងម៉េច ចង ដើរចង?

ណាម :	ចងស្លាបសេកបណ្ដើរទៅវិញទៅ ។

ដានី :	អត់មានគំរាម គេគំរាមថាម៉េចខ្លះ?

ណាម :	គេគំរាមថាយើងរត់ចោលជួរ.....(ស្ដាប់មិនបាន) ប៉ុនខ្ញុំគេប្រមាថយ៉ាងណា ក៏ខ្ញុំមិនដែលត ទេ ។

ដានី :	គេប្រមាថថាយ៉ាងម៉េចខ្លះ?

ណម ៖ គេប្រមាថយកយើងទៅសម្លាប់ចោល ធ្វើម៉េចក៏ធ្វើទៅ ជីវិតត្រូវងាប់ក៏ងាប់ក៏នឹកតែក្នុងចិត្តខ្លួនឯង..........កាលដែលយួនចូល(សម្លេងរំខានជាច្រើន) ។ និយាយពីយកយើងទៅបានប៉ុន្មានខែ ក៏មានចាប់យកទៅសម្លាប់ចោលអស់ទៅ មានអ្នកថ្មីមកក្តាប់ទៀតទៅ បន្តគ្នាច្រើនណាស់ ។ ម៉ាជំនាន់សង្គមជំបូងបង្អស់ អ្នកពីកើតមកក្តាប់ៗមក មានអ្នកពីណាមកទៀតមាន៣-៤គន្លាក់ដូចថា ម៉ាជំនាន់មកក្តោបក្តាប់រួចមានខុស គេយកទៅសម្លាប់ចោលម៉ាសារ ។

ដានី ៖ ចុះមីងកាលមីងទៅដំបូង ឈ្មោះតាខ្មិន អ្នកដឹកនាំទៅ ហើយចល័តគណៈស្រុកព្រះនេត្រព្រះឈ្មោះតាវ៉ាល់ ឈ្មោះតាមោង ហើយគាត់ធ្វើប្រធានចល័តតំបន់៥ទៀត?

ណម ៖ ចាំ!

ដានី ៖ កាលនឹងល្បឿននឹង?

ណម ៖ ចាំ!

ដានី ៖ កាលនឹងគណៈតំបន់៥ឈ្មោះអីទៅ?

ណម ៖ គេហៅតាស្អីណាទេ ខ្ញុំមិនស្គាល់ទេ ព្រោះតែគេថាតា តែខ្ញុំមិនដែលឃើញ ដូចថាពេលដែលគេចុះទៅក៏យើងមិនដែលបានទៅឃើញ ។

ដានី ៖ ដែលព្រោះឈ្មោះ តាហឹង្សដែរអត់?

ណម ៖ ទេ! ដូចមិនមាន ។

ដានី ៖ តាជៀលអីដែរព្រោះ?

ណម ៖ ស្គាល់តែយាយថែម តាជៀលអត់ដឹងទេ បើពួកខ្ញុំនៅចល័តនៅពោធិ៍៣ដើម យាយថែមនៅភ្នំលាភអ្នកទំនប់កណ្តាល ។

ដានី ៖ យាយថែម?

ណម ៖ ចាំ! ហ្នឹងយាយថែម ។

ដានី ៖ ចឹងកាលមីងលើកទំនប់ត្រពាំងថ្ម ដែលព្រោះយាយថែមក្តោបក្តាប់ដែរ?

ណម ៖ អត់ទាន់ក្តាប់ទេ ពីត្រឹមខ្ញុំមកនៅគ៣ដើមនេះ ព្រោះតែគេថាយាយថែមខទៅប្រជុំនៅភ្នំលាភ ។ ប៉ុនខ្ញុំមិនដែលទៅឃើញមុខគេទេ ព្រោះតែគេថា ប្រធានគេទៅប្រជុំៗភ្នំលាភ និយាយចេះ ។

ដានី ៖ ចុះតាវ៉ាល់ តាមោង នឹងគាត់នៅរហូត ឬក៏យ៉ាងម៉េច?

ណម ៖ ទេ! ទៅបាត់ទាំងអស់បានធ្លាក់មកយាយថែម វាមកម៉ាគន្លាក់ៗច្រើនគ្នា ។

ដានី ៖ កាលនឹងតាវ៉ាល់?

ណាម ៖ តាវ៉ាល់រួច បានអាពួកៗ ប៉ិឈួន អឺ! ច្រើនគន្ធាក់ណាស់ វ៉ាដូចម៉ាសារទៅចាប់ទៅ អត់ៗ

ដានី ៖ ចឹងចប់ពីតាវ៉ាល់គណៈស្រុកទៅ តាវ៉ាល់នឹងទៅណាទេ?

ណាម ៖ ឮតែគេថាចាប់យកវ៉ៃចោលៗ មិនដឹងបាត់រូបទៅ អត់តាវ៉ាល់ដួប អត់ម៉ាជាន់ទៀត ឈួនៗ បាត់តាឈួនទៅ ពួកៗហើយស្អីទេៗ

ដានី ៖ ចុះតាវ៉ាល់ តាមោងគណៈស្រុក ដល់ពេលគេចាប់តាវ៉ាល់តាមោងទៅគេដាក់ឈ្មោះឈួន?

ណាម ៖ ទេ! មានប្រជាជនថ្មីមកនៅទៀត នឹកឃើញថាប្រធានថ្មីមកៗ

ដានី ៖ ប្រធានថ្មីឈ្មោះអីគេ ឈ្មោះឈួន?

ណាម ៖ អត់ដឹងគេធ្វើអី គ្រាន់តែគេថាគេមកនៅក្តាប់ចល័តៗ

ដានី ៖ ក្តាប់ចល័តតំបន់?

ណាម ៖ គេមានកាំភ្លើងមានអីៗ

ដានី ៖ ចល័តតំបន់៥នឹង?

ណាម ៖ នោះឯង ចល័តតំបន់ពួកខ្ញុំៗ

ដានី ៖ ចុះគណៈស្រុក?

ណាម ៖ គណៈស្រុកបក្សពួកចៅហ្វាយខេត្តៗ

ដានី ៖ មានគណៈស្រុកថ្មីឈ្មោះអីទៅ?

ណាម ៖ គណៈស្រុកនោះខ្ញុំមិនដឹងទេ មកនៅនេះ ប៉ុនខ្ញុំនៅតែចល័តៗ

ដានី ៖ ចុះចល័តធំជាងគេ អ្នកគ្រប់គ្រងជាងធំនៅត្រពាំងថ្មៗ ចុះមុនដំបូងមឹងថាឈ្មោះតាវ៉ាល់ តាមោង?

ណាម ៖ បាត់តាមោង មានអ្នកធំជាងតាមោង តាវ៉ាល់ទៀត មិនដឹងជាអ្នកណាទេៗ

ដានី ៖ ប៉ុន្តែចប់ គេចាប់តាវ៉ាល់ តាមោងហើយពីណាទៀត មកគ្រប់គ្រងចល័តនឹង នៅកន្លែង ត្រពាំងថ្ម?

ណាម ៖ ត្រពាំងថ្មនឹងគេរំសាយហើយ លើកបានរួចបានគេរំសាយដាក់ម៉ាទីតាំងម៉ាស្រុកៗមកវិញៗ ទៅបានពួកខ្ញុំមកនៅគ៣ដើម ទៅគេហៅរួមទៀតម៉ិៗគេហៅប្រជុំទៅ គេថាទៅប្រជុំផ្ទះយាយ ចែមៗ ៗ ខ្ញុំមិនដែលស្គាល់ទេ ផ្ទះយាយចែមៗ

ដានី ៖ ចឹងមឹងលើកទំនប់នឹងរយៈពេលប៉ុន្មាន?

ណាម ៖ ប៉ុន្មានខែដែរ មើលមិនដូចជាមិនយូរទេ ចាប់ពីត្រឹមច្រូតមកដល់ខែយើងធ្វើស្រែនេះរួចអស់ហើយ ខែវដូវយើងធ្វើស្រែវស្សានេះរួចហើយ ។ បានពួកខ្ញុំដកចល័តធ្វើស្រែបណ្ដោយនោះរួចអស់ហើយទំនប់ ។

ដានី ៖ ចុះលឿនម៉េច?

ណាម ៖ លឿន រយៈកាលប៉ុន្មាន៥ខែលើក ថាយ៉ាងច្រើន៥ខែ ។

ដានី ៖ ៥ខែ ពីចុង៧៦មីងទៅលើក?

ណាម ៖ ចា៎!

ដានី ៖ ច្រូតស្រូវនឹងហើយ ឆ្នាំណាបានចប់?

ណាម ៖ ចាំមើលខ្ញុំលើកណាទៅពីពេលកំពុងច្រូតស្រូវវស្សារួចចូលឆ្នាំៗនៅនោះឯង ពីព្រោះគេយកកុនមកឲ្យមើល គេថាចូលឆ្នាំ យើងមិនដឹងថាចូលឆ្នាំថ្ងៃណាទេណា គេមានកុនបដិវត្តគេទៅបញ្ចាំងឲ្យមើលនៅភូមិពង្រម៉ាយប់ ។ ឲ្យយើងសម្រាក២ថ្ងៃ គេចូលឆ្នាំ សម្រាក២ថ្ងៃនោះមិនឲ្យទៅណាទេ គេឲ្យយើងសម្រាក ។ ដល់ពេលរួចទៅបានចាប់ផ្ដើមធ្វើទៀត ចូលឆ្នាំទៀតរួចធ្វើ ដូរទីតាំងទៅនៅខាងកើត ។

ដានី ៖ ចុះមីងដំបូងនៅកន្លែងលើកជិតភូមិ?

ណាម ៖ នៅលិចតាវ៉ង អឺ!នៅខាងកើតតាវ៉ង ។

ដានី ៖ នៅជិតភូមិតាវ៉ង ខាងកើតតាវ៉ង ដល់ពេលចប់ពីនឹងតទៅណាវិញទៀត?

ណាម ៖ ទៅអែបត្រពាំងថ្ម ។

ដានី ៖ ទៅអែបត្រពាំងថ្ម?

ណាម ៖ ចា៎! ដល់ចេញពីត្រពាំងថ្មទៅនៅភូមិពង្រ ។

ដានី ៖ ចុះមីងកាលមីងនៅអែបតាវ៉ងនឹង លើកនឹងរយៈពេលប៉ុន្មាន បានទៅអែបត្រពាំងថ្ម?

ណាម ៖ មិនដឹងចេញប៉ុន្មានថ្ងៃទេ ។

ដានី ៖ យូរទេ?

ណាម ៖ យូរគ្រាន់ដែរ រយៈកាលប្រហែលម៉ាខែដឹង បានទៅទៀតទៅ ។

ដានី ៖ ទៅកន្លែងអែបត្រពាំងថ្មវិញ?

ណាម ៖ ចា៎! ដល់ទៅអែបត្រពាំងថ្មរយៈកាលប្រហែលម៉ាខែដាងក៏ទៅទៀត ។

ដានី ៖ ទៅណាទៀតទៅ?

ណាម ៖ រុញទៅដើង ។

ដានី ៖ ទៅដើរនៅណា?

ណាម ៖ ទៅនៅភូមិពន្រ្ទ ។

ដានី ៖ ទៅភូមិពន្រ្ទ?

ណាម ៖ ចា៎! ដល់ចេញពីភូមិពន្រ្ទ បានទៅនៅវាលស្រែចេញនោឯកើតកូនខ្វែងចុង ។

ដានី ៖ កើតកូនខ្វែងទៀត?

ណាម ៖ ទៅដើរ គេថានៅអែបណាំគាវ តែមិនដែលឃើញភូមិគេទេ ។

ដានី ៖ មិនដែលឃើញ?

ណាម ៖ មិនដែលឃើញ គេថានៅអែបណាំគាវ មិនដែលឃើញភូមិគេទេ បើខ្ញុំចូលទៅព្រៃខាងកើត នោះសុទ្ធតែព្រៃៗ ឈើធំៗ ឡើងហែលៗ ។

ដានី ៖ មីងខស្សរាហ៍ជួបតាវ៉ាល់ តាមោង?

ណាម ៖ តាវ៉ាល់នេះឯង ចង់បាញ់ខ្ញុំចោល ។

ដានី ៖ តាវ៉ាល់ តាមោងចង់បាញ់ៗ កាលនឹងមីងនៅកន្លែងណាដែលតាវ៉ាល់ចង់បាញ់ចោល?

ណាម ៖ នៅជាប់នឹងកន្លែងគេហៅស្ពានរាប ។

ដានី ៖ នៅជិតភូមិតាវ៉ែង?

ណាម ៖ ទេ! នៅកើតពាក់កណ្តាលត្រពាំងថ្ម ជិតដល់តាវ៉ែង នៅកើតៗតាវ៉ែងឆ្ងាយ ដែលសព្វថ្ងៃទៅរកមិនឃើញទេ អត់ដឹងគេកាត់ចោល ។

ដានី ៖ ចុះកាលនឹងមានពេលគេប្រជុំអីដែរ?

ណាម ៖ អូ! ប្រជុំតែគេ ពួកយើងដែលប្រជុំ ។

ដានី ៖ អត់ដែលប្រជុំទេ?

ណាម ៖ ដូចថាម៉ីៗគេទៅប្រជុំទៅ យប់ឡើងក៏គេមកប្រាប់យើងទៅ ថាយប់ឡើងចេះគេថាធ្វើការម៉ាភ្លែតក៏គេមិនដែលប្រជុំយូរទេដែលយើងដើយណា ។ គេហៅយើងថាកន្លែងប្រជុំម៉ាឃុំនឹងប្រាប់ថា ការងារយើងត្រូវសំរុកប៉ុន្មានថ្ងៃឲ្យរួច ។

ដានី ៖ ពួកតាវ៉ែង ពួកតាអីមកពីកើតមក?

ណាម ៖ គេថាអ្នកកើតៗ ប៉ុន្តែខ្ញុំមិនដែលដឹង ។

ដានី ៖ អ្នកកើតខាងណា?

ណាម ៖ ខេត្តណាឆ្ងាយៗ ។

ដានី ៖ ខេត្តណាឆ្ងាយៗ?

ណាម ៖ ខាងវ៉ារិន ខាងណាទេ ។

ដានី ៖ ខាងសៀមរាប វ៉ារិននឹង?

ណាម ៖ នឹងហើយ ដែលអ្នកក្តាប់ខ្ញុំក្រោយ ឈ្មោះ ឈូងនោះ អ្នកវ៉ារិន ។

ដានី ៖ ឈ្មោះ ឈូង?

ណាម ៖ ចា៎!

ដានី ៖ អ្នកវ៉ារិន?

ណាម ៖ ចា៎! បើអ្នកក្តាប់ឈ្មោះតាស្មិននេះ គេហៅស្រុកណាទេ ក្របីរៀល ឯណាទេ បើថាតាមោង តាវ៉ាល់ ខ្ញុំមិនដែលបានជួបនិយាយអីទេ ។ គាត់គ្រាន់តែប្រមាថខ្ញុំទៅ ខ្ញុំឃើញគេទៅ បើ តាមោងរៀងទាប តាវ៉ាល់រៀងខ្ពស់ ស្តើង ។ តាមោង តាវ៉ាល់នោះ បងប្អូនគេបង្កើត ។ បងប្រធាន ប្អូនអនុប្រធានក្តាប់ស្រុកព្រះនេត្រព្រះ ខ្លាំងណាស់តានោះ ខ្លាំងណាស់ធ្វើទំនប់ ។ គាត់ខ្លាចកាលបិទទំនប់នេះ ខ្មោចចូលនារី នេះទំនប់គោកកីកាត់ស៊ីងគោកកី បិទឆ្ងាយៗ បិទ អត់ជាប់ទេ ។ ដល់ទៅយប់ឡើងមកពន្យល់សប្តិដល់គាត់ៗខ្លាច បានជាអាចធ្វើស្ពាន អាទំនប់ គោកកីនេះណា ធ្វើស្ពានរួច មិនទាន់ធ្វើរួចណា ទើបបោះបង្គោលក៏ស្រុកគេចប់ ។ អាស្ពាន កាត់ស៊ីង ពួកខ្ញុំបិទៗជិតឆ្ងាយៗ ។

ដានី ៖ គោកកី ទំនប់គោកកីនៅណា?

ណាម ៖ អាកន្លែងគោករំចេកទៅកើត ។

ដានី ៖ នៅភូមិណា?

ណាម ៖ នៅភូមិគោកកី អាទំនប់ចេញពី ។

ដានី ៖ នៅឃុំព្រះនេត្រព្រះយើងដែរ?

ណាម ៖ ចា៎! ឃុំនេះភ្នំលាភ ។

ដានី ៖ ឃុំភ្នំលាភ?

ណាម ៖ ចា៎!

ដានី ៖ ចឹងតាមោង គាត់ទៅបាត់ទៅឈ្មោះឈូងឡើងវិញ?

ណាម ៖ ចា៎! បន្ទាប់ពីឈូងទៅទៀត មានស្រីៗ ក្មេចឈ្មោះស្រី ។

ដានី ៖ ចុះឈ្មោះប៉ុអីមិញ?

ណម : តាពូត បាត់ពីប៉ិល្លូងចូលតាពូត បាត់ពីតាពូតនោះអាល្បឿង ហើយកាលនោះពួកវា២-៣ខែ បាត់ៗ មិនដឹងជាទៅណាទៅ គ្រាន់តែគេថាដូរៗ ។ ប៉ុនគ្រាន់តែឃើញឡានមកដឹកៗចង សុទ្ធតែចងកាលនោះ ។ ដល់ពេលឡើងមកបាននិរតីចូលមក ។

ដានី : និរតីហ្នឹង?

ណម : និរតីទឹកចុងក្រោយ ។

ដានី : និរតីនឹងពីណាគេ?

ណម : ក្មេចឈ្មោះនិរតីៗមិននៅបានយូររយៈកាលមិនយូរទេ មិនបាន៤-៥ខែ ។

ដានី : និរតីមកធ្វើធំៗ?

ណម : និរតីមកធំៗណាស់..... ។

ដានី : ពីណាគណៈស្រុកព្រះនេត្រព្រះ?

ណម : អត់ស្គាល់ព្រោះខ្ញុំនៅចល័ត ។

ដានី : ចុះយាយថែម?

ណម : យាយថែមនោះឯងគេថាគណៈស្រុកព្រះនេត្រព្រះ ប៉ុនខ្ញុំមិន យាយថែមនៅភ្នំលាភ ។

ដានី : គាត់នៅភ្នំលាភ?

ណម : អត់មាននៅនេះទេ គេហៅគណៈស្រុកៗយាយថែមៗអត់ពីតាមោង តាវ៉ាល់ ។ ប៉ុនខ្ញុំមិនដែលឃើញ ។

ដានី : អត់ពីតាមោង តាវ៉ាល់មក យាយថែម?

ណម : កាលនោះដឹងថាគេធំគណៈស្រុក គេក្តាប់ចល័តទៀត ចប់បណ្តោយ គេក្តាប់២ដាប់តែគេ ។

ដានី : គេក្តាប់ម៉េចគេ?

ណម : ដូចថាគេធ្វើចៅហ្វាយស្រុករួច គេក្តាប់ចល័ត២គង់ ពួកខ្ញុំធ្វើស្រែបានណាស់ ប៉ុនមិនដឹងយកស្រូវទៅណាទេ ច្រើនណាស់ចល័ត ។

ដានី : ចុះមីងលើកទំនប់ ត្រពាំងថ្ម ហើយឆ្នាំណា?

ណម : ឆ្នាំ៧៧នោះឯង មិនបានយូរទេ លើកទំនប់ត្រពាំងថ្មរយៈកាល ។

ដានី : ខែប៉ុន្មាន?

ណម : មិនដឹងខែប៉ុន្មានទេ ខ្ញុំចាំបានថាចាប់លើកពីខែច្រូត ដល់ខែធ្វើស្រែនេះរួចហើយ បើខ្ញុំចុះមកធ្វើស្រែបណ្តោយ ។

ដានី ៖ ធ្វើស្រែនៅណា?

ណម ៖ ធ្វើស្រែម៉ាដួរព្រៃមាន់ ម៉ាដួរគោករំចេក ។

ដានី ៖ ចុះមីងថាទៅកន្លែងគ៣ដើម?

ណម ៖ នោះឯង គេហៅភូមិគ៣ដើម ខាងត្បូងភូមិគោករំចេកមក ត្រង់នោះមានដើមគ៣ដើម ទៅនៅខាងនោះម៉ាកន្លែង ទួលរវៀងម៉ាកន្លែង នឹងព្រៃមាន់ ។

ដានី ៖ អានឹងក្នុងស្រុកភ្នំស្រុក?

ណម ៖ ចាំ! តែពួកខ្ញុំចល័តតំបន់ ។

ដានី ៖ មីងចូលចល័តតំបន់?

ណម ៖ ចាំ! ចូលចល័តតំបន់ម៉ាកន្លែង គោករំចេក ទួលរវៀង គ៣ដើម ព្រៃមាន់នេះ គេចូលចល័ត តំបន់ហើយ ។

ដានី ៖ តំបន់ប៉ុន្មាន?

ណម ៖ ហៅតំបន់៥ ។

ដានី ៖ ពីណាគេប្រធានចល័តតំបន់៥ ?

ណម ៖ ប្រធានធំ ដូចខ្ញុំថាចឹងមានបណ្តើរៗ ។

ដានី ៖ ពីណាគេ?

ណម ៖ គេហៅថា ពេលខ្លះឃើញយាយបែមប្រជុំ ពេលខ្លះ មិនដឹងជាអ្នកណាគេទេ ខ្ញុំអត់ស្គាល់គេទេ យាយបែមៗ ក៏ខ្ញុំមិនដែលបានទៅមើល ។

ដានី ៖ ឃើញគាត់អត់?

ណម ៖ អត់ដែលបានឃើញថារូបរាងយ៉ាងម៉េច ពុតែតាមគេដែលយើងប្រជាជនយើងមិនដែលទៅចាប់អារម្មណ៍ ។

ដានី ៖ ចុះក្រែងមីងធ្លាប់ទៅប្រជុំជាមួយគាត់?

ណម ៖ អត់ដែរទេ រឿងដែលថាបើកវគ្គ(រៀបការ) ទៅមែនដូនគ្នាយើងដូចថា គេបានគ្រួសារចឹង ហើយប្រធាននេះគេថាជូនមិត្តនេះទៅៗ គេបណ្តោយយើងជូនយើងជូនទៅបើកទៅ ។ បើថា ទៅប្រជុំៗយាយបែម ខ្ញុំមិនដែលបានទៅទេ ។

ដានី ៖ ប៉ុន្តែយាយបែម ផ្ទះគាត់នៅភ្នំលាភ?

ណម ៖ ចាំ!

ដានី ៖ ផ្ទះគាត់នៅភ្នំលាភ?

ណម ៈ ចា៎!

ដានី ៈ ចុះសាលាស្រុកព្រះនេត្រព្រះនៅណា មន្ទីរស្រុក?

ណម ៈ មន្ទីរស្រុកកាលដែលតាមោង តាវ៉ាល់នៅអែបវត្តលោកគ្រូដៃ ហ្នឹងផ្ទះតាមោង តាវ៉ាល់នៅ។

ដានី ៈ ដល់យាយថែម គាត់មកនៅនឹង?

ណម ៈ យាយថែមនៅភ្នំលាភ ពួកគេថានៅភ្នំលាភ។

ដានី ៈ ភ្នំលាភនៅណា?

ណម ៈ នៅខាងកើត។

ដានី ៈ ខាងកើត?

ណម ៈ ខាងកើតព្រៃមាន់ ខាងកើតរំដួល ប៉ុនផ្ទះគាត់នៅត្រង់ណាអត់ដឹងទេ។

ដានី ៈ មីងអត់ដែលទៅជាមួយគាត់?

ណម ៈ អត់ទេ។

ដានី ៈ ចុះមីងថាមិញ គាត់ទៅ ពេលចល័តតំបន់អីទៅ គាត់ទៅប្រជុំ?

ណម ៈ អត់ដែលហៅទៅៗ ហៅតែប្រធានៗទៅប្រជុំរួចបានប្រធានមកប្រាប់ការងារគេទៅទៀត ដែលហៅទៅទាំងអស់ គេហៅតែមេធំៗទៅ។ ដល់មេធំៗមកម៉ាទីតាំងយើងប្រាប់យើងទៅ គេគិតថាយើង។

ដានី ៈ ចឹងទៅលើកទំនប់ត្រពាំងថ្មនឹង លើកពេលទៅដំបូង ពេលច្រូត?

ណម ៈ ចា៎! ច្រូតស្រូវវស្សា។

ដានី ៈ ដល់ពេលចប់ មីងដកចេញមក ពេលគេ?

ណម ៈ រដូវធ្វើស្រែនេះ។

ដានី ៈ រដូវធ្វើស្រែឆ្នាំ៧៧?

ណម ៈ ចា៎!

ដានី ៈ រដូវធ្វើស្រែឆ្នាំ៧៧នឹង ដកចេញមកវិញ?

ណម ៈ ចា៎!

ដានី ៈ មកនៅគ៣ដើម នៅកន្លែងគោករំចេក នៅកន្លែងព្រៃមាន់?

ណម ៈ ចា៎! ខ្ញុំនៅធ្វើស្រែបាន២ឆ្នាំ។

ដានី ៈ ធ្វើស្រែបានប៉ុន្មានឆ្នាំ?

ណម ៖ ២ឆ្នាំបានយួនចូលនៅចល័តគ៣ដើម ។

ដានី ៖ ម៉េចបាន២ឆ្នាំ បើមីងថា?

ណម ៖ ចុះ៧៧ ៧៨ ៧៩ ចុង៧៩ហើយ ដែលវៀតណាមចូលកំពុងច្រូតស្រូវទៀត ខ្ញុំចាំបាន ។ ពួកខ្ញុំច្រូតស្រូវប្រមូលគ្រាប់ស្រូវនៅពេញលាន ដែលនាំគ្នារត់ ខ្ញុំរត់មកនៅផ្ទះខ្ញុំនេះ ខ្ញុំនាំម៉ែបងប្អូនខ្ញុំទៅច្រូតស្រែរនាម ច្រូតមិនទាន់រួចច្រូតយកស្រូវអាឆ្នាំវៀតណាមចូលនោះ ។ ខ្ញុំនៅ ធ្វើបាន២ឆ្នាំ ប៉ុន្តែអាឆ្នាំដែលយើងរត់នេះស្រូវប្រមូលមិនទាន់អស់ទេ ។

ដានី ៖ គណៈតំបន់អី មីងអត់ស្គាល់គេ?

ណម ៖ អត់បានទេ អត់ដែលស្គាល់ ។

ដានី ៖ ចុះមីងកាលជំនាន់នឹង គេចាប់ គេសម្លាប់អីដែរអត់?

ណម ៖ អូ! ភាគច្រើនដេកជុំគ្នាអ្នកថ្មី រកសម្លាប់ក៏សម្លាប់ ឃើញតែមុខ ។

ដានី ៖ ឃើញតែមុខ?

ណម ៖ ចា៎! ប៉ុនយើងមិនហ៊ានសួរនាំគេ ។

ដានី ៖ ច្រើនតែអ្នកស្រុក?

ណម ៖ អ្នកថ្មីក៏មាន អ្នកចាស់ក៏មាន សូម្បីតែត្រឹមថាដូចថាគេស៊ើបប្រវត្តិថាយើងចេះចុះក៏យប់ឡើង គេហៅទៅ ។

ដានី ៖ ស៊ើបប្រវត្តិម៉េច?

ណម ៖ ប្រវត្តិដូចថាយើងមានខ្សែស្រឡាយ កូនអ្នកតូច អ្នកធំទៅក៏ដឹងថាសម្លាប់ហើយ ។ អឺ!មួយទៀតស៊ើបដឹងថា យើងគេចវេសការងារហួសក៏គេវៃចោល ដូចថាថ្ងៃនេះក៏ឈឺៗ គេតាមដានដឹងថាចំនួនតែ៣-៨ថ្ងៃ យើងមិនឈឺគេវៃចោល ។ បានថាយើងអ្នកមិនក្រឡេចក្រឡុចធ្វើការទៅ បានយើងបានរស់ លើកទំនប់ចល័ត៤-៥ថ្ងៃ ខ្ញុំមិនដែលឈឺម៉ាថ្ងៃទេ វែកដីឡើង រាប់ ។

ដានី ៖ ចុះកាលមីងទៅវែកដីនៅត្រពាំងថ្មនឹង កាលនឹងមានគេចាប់ទេ កំពុងតែវែកដី?

ណម ៖ ពួកប្រជាជនថ្មីក៏ចាប់ ប្រជាជនចាស់ក៏ចាប់ យកទៅសម្លាប់ ។

ដានី ៖ គេចាប់យកទៅសម្លាប់នៅណា?

ណម ៖ ដឹងគេវៃចោលណាទេ ខ្ញុំដែលដឹង ។

ដានី ៖ អត់ដែលដឹង?

ណម ៖ មិនដឹងគេកប់ពេលណា គេថាកប់ឆ្ងាយ ប៉ុនយើងមិនដែលបានទៅមើល ខ្ញុំមិនដែលបាន ទៅមើលថាគេសម្លាប់ ។

ដានី ៖ អត់ដែលឃើញកន្លែងគេសម្លាប់?

ណម ៖ ឃើញ ប៉ុនយើងមិនបានមើល កន្លែងគេកប់ក៏ឃើញ ។

ដានី ៖ ចុះកន្លែងគេដាក់គុកអីមានអត់?

ណម ៖ ទេ! ម៉ាជួរខ្ញុំអត់មានទេ ។

ដានី ៖ អត់មានទេ តែគេចាប់យកទៅសម្លាប់ម៉ង?

ណម ៖ ចាប់បាត់ជ្រាបៗ កន្លែងខ្ញុំអត់មានគុកឲ្យគេនៅទេ ។

ដានី ៖ ចុះអ្នកដែលដើរចាប់គេនឹង មីងស្គាល់ទេ?

ណម ៖ គេងាប់បន្តគ្នាអស់ហើយ ។

ដានី ៖ ឈ្មោះអី ប៉ុន្តែមីងស្គាល់ឈ្មោះគាត់ទេ?

ណម ៖ ទេ! មិនបាន ដែលស្គាល់សព្វ ដល់ព្រឹកឡើងក៏សួរនាំគ្នាទៅ ដល់ព្រឹកឡើងបាត់មិត្តនេះ បាត់មិត្តនោះ ក៏ ។

ដានី ៖ បាត់ច្រើនទេ អ្នកទៅលើក?

ណម ៖ អូ! បាត់ច្រើន ។

ដានី ៖ ចុះមីងត្រូវគេចងតែម្តងទេ ដល់ពេលដែលមីងមកលេងផ្ទះ?

ណម ៖ ចា៎!

ដានី ៖ ឆ្នាំណាដែលមីងមកលេងផ្ទះ ដែលគេចងនឹង?

ណម ៖ កាលនឹងជួយលើកចល័តបានប្រហែល៣ខែ ។

ដានី ៖ ចល័តណា?

ណម ៖ ចល័ត...ខ្ញុំចូលចល័តគត៣ដើម ខ្ញុំចូលខែវស្សា ខែប្រូតស្រូវរួច ខ្ញុំមកធ្វើស្រែដល់ខែប្រូត ។

ដានី ៖ បានន័យថាមីងទៅលើកទំនប់នៅត្រពាំងចប់អស់ហើយ?

ណម ៖ ចា៎! ចប់អស់ហើយ ដែលខ្ញុំមកនៅចល័តៗរួចខ្ញុំធ្វើស្រែឡើងរួចប្រូតឡើងរួចបានខ្ញុំសុំគេមក លេងផ្ទះ ដល់មកខ្ញុំអត់បានមកលេង ។ កាលនោះកងខ្ញុំធ្វើស្រែប្រាំង ។

ដានី ៖ បុព្វតនឹង ឲ្យកូនចៅឈ្មោះចកមកចាប់?

ណម ៖ ចា៎!

ដានី ៖ គ្នាប៉ុន្មាននាក់មកចាប់?

ណាម ៈ មកចាប់ខ្ញុំតែ២នាក់ ។

ដានី ៈ តែចាប់តែមីងម្នាក់ទេ?

ណាម ៈ ទេ! ម៉ាឃុំព្រះនេត្រព្រះដាង៣០នាក់ ដែលយកគ្រប់ភូមិដែលមកចល័ត ពីណាពីណែដែលចល័តឲ្យតែអ្នកចល័តគេចាប់ទៅវិញទាំងអស់ ។

ដានី ៈ ពីណាខ្លះដែលមីងចាំ ដែលគេចងទៅវិញ?

ណាម ៈ អឺ!មិននេះទេ មិនចាំបាន ខ្ញុំ២នាក់មីងមួយនោះនៅជុំខ្ញុំងាប់ហើយ ។

ដានី ៈ ឈ្មោះអី?

ណាម ៈ ឈ្មោះ សៀន ។ ងាប់នឹងជម្ងឺដែលវ៉ៃ អាយួនចូលវាបានប្ដីកូន២វាងាប់ ២នាក់ខ្ញុំដែលវាចងយកទៅ ។

ដានី ៈ តែ២នាក់នឹងទេ?

ណាម ៈ ចា៎! ភូមិខ្ញុំ២នាក់ ភូមិប៉ោយព្រីង ប៉ោយសំរោង ដើងវត្ត ម៉ាឃុំព្រះនេត្រព្រះនេះគ្រាន់តែគេ ចងយកទៅបណ្ដើរ៣០នាក់.....(ស្ដាប់មិនបាន) ។ ភូមិស្ដីភូមិកំពង់ត្រាច ដល់ពេលថ្ងៃឡើងក៏ ។

ដានី ៈ ជំនាន់គេចងយកទៅ ប៉ុព្វតនឹង?

ណាម ៈ ចា៎!

ដានី ៈ យាយថែម អត់ទាន់ព្ទ្បុឈ្មោះយាយថែមមក?

ណាម ៈ ព្ទ្បុ។ហើយ ប៉ុន្តមិនដែលដឹងថាគេនៅណា ព្ទ្បុថាយាយថែម។ជិតមកក្ដាប់ គេថាចឹង ។ ដល់ពេលយាយថែមមកនេះ វាបាត់អាពួកនឹងទៅ ប៉ុន្តអាពួកខ្ញុំឃើញគេចងដាក់ឡានដឹងតែឃើញ ព្រោះខ្ញុំកំពុងតែស្ទូងស្រូវ ចុះយើងសម័យនោះ ដែលមានខែវស្សា ខែប្រាំង យើងមានដឹង ចុះបើយើងធ្វើស្រែរួចប្រាំងទាំងវស្សា ប្រូតរួចពន្រាបដីធ្វើ។ ។

ដានី ៈ តែពួក។ឃើញគេចងដាក់ឡាន ចុះយាយថែម?

ណាម ៈ យាយថែម រត់ដែលយួនចូល រត់រហូត ផ្លូវភ្នំស្រុក យាយថែមមានអាគ្រាក់រត់ ។ កាលនោះសិនជាគាត់កៀងគរកម្លាំងខ្លួនខ្ញុំក៏បាន ប៉ុន្តគាត់រត់ទៅតែខ្លួន យកតែអំបិល និងអង្ករចេញផ្លូវភ្នំស្រុកទៅចេះ ។ បើយើងក៏គេទៅអស់ ។

ដានី ៈ ចុះមីងអត់ដែលស្គាល់គាត់ អត់ដែលឃើញមុខគាត់?

ណាម ៈ អត់ដែល ខ្ញុំអត់ដែលឃើញយាយថែមទេ ព្ទ្បុតែគេថា ។

ដានី ៖ ចុះយាយថែមយ៉ាងម៉េចដែរ?

ណម ៖ បើខ្ញុំអត់ដែលបានឃើញ ។

ដានី ៖ គាត់មកគ្រប់គ្រងហ្នឹងយ៉ាងម៉េច គាត់កាចសាហាវ?

ណម ៖ ទេ! នៅពួកខ្ញុំក៏មិនដែលទៅចុះដាប់ ខ្ញុំមិនដឹងថាគាត់កាចទេ ។ បើមិនដែលបានទៅឃើញផ្ទាល់ មិនដែលថាកាចម៉េច បើយើងឃើញគេទៅចុះការងារជុំយើង ។

ដានី ៖ ចុះពេលដែលគាត់មកនឹង ពួកកម្មាភិបាលចាស់ៗ ដូចពួកប៊ិពួកប៊ិអីនឹង ពេលដែលគាត់មកបានគេចាប់ ឬក៏គេចាប់មុនគាត់មក?

ណម ៖ គេចាប់ម៉ាថ្ងៃ២ចេះ ក៏មានអ្នកក្តោបក្តាប់ចុះទៅក្តាប់ទៀតទៅ ដូចថាបាត់ម៉ាសារក៏២-៤-៥ថ្ងៃក៏មានអ្នកផ្សេងទៅក្តាប់ទៀតទៅ មានតែប៉ុននោះឯង ហើយយើងប្រជាជនដែលហ៊ានសួរគេ ។ គេគ្រាន់តែមកក្តាប់ថ្មីៗប៉ុននោះ ។ គេមកដឹកនាំយើងថ្មី ។

ដានី ៖ ប៉ុន្តែកន្លែងអាងត្រពាំងថ្ម អត់ដែលឃើញយាយថែមទៅ?

ណម ៖ ទេ! មិនដែលឃើញ ឃើញតែពួកតាមោង តាវ៉ាល់គេហៅតាញឹមៗ ។

ដានី ៖ តាញឹមនៅណា?

ណម ៖ គេហៅប្រធានមជ្ឈិមនៅណា នៅបៀតតា ប៉ុនខ្ញុំមិនដែលឃើញទេ តាញឹមនោះ ។

ដានី ៖ តាញឹមនោះ មកកន្លែងត្រពាំងថ្មនឹងដែរ?

ណម ៖ ចា៎! ឮតែគេថាតាញឹមមកៗ ហៅប្រជុំម៉ិៗទៅប្រជុំនឹង ប៉ុនយើងមិនដែលឃើញគេ ដឹងគេប្រជុំឯណា ។

ដានី ៖ ចុះជៀលអី ដែលឮឈ្មោះ ប៉ិជៀលៗ?

ណម ៖ ឮឈ្មោះ ក្នុងចល័តនោះ ថាតាជៀលទៅប្រជុំក៏ឮ ប៉ុនយើងមិនដែលឃើញឈ្មោះ ។

ដានី ៖ តាហឹងស្រអីដែលឮ?

ណម ៖ បើហឹងស្រនោះមិនដែលឮទេ តាញឹម តាជៀល ឮ ប៉ុន្តែយើងមិនដែលឃើញរូបរាងគេយ៉ាងម៉េច ដូចថាថ្ងៃនេះគេមកប្រជុំទៅ យើងទៅប្រជុំនៅណា យើងមិនដែលដឹងទេ យើងគិតតែពីវែក ។

ដានី ៖ ចុះយាយថែមអត់ដែលឮថាគាត់ទៅប្រជុំនៅ?

ណម ៖ កាលម៉ាហ៊ីកទំនប់ត្រពាំងថ្ម គាត់មិនទាន់មានទេកាលនោះ គាត់ទើបម៉ាវគ្គក្រោយ ។

ដានី ៖ ចុះមីង ពេលដែលមីងដកចេញនឹង គេធ្វើហើយ ឬក៏គេដកមីងចេញ ក៏គេដាក់អ្នកផ្សេងឲ្យមកធ្វើវិញនៅត្រពាំងថ្មនឹង?

ណម ៖ ត្រពាំងថ្ម ធ្វើឡើងរួចស្រេច ដកកម្លាំងចេញមកនៅតាមការដ្ឋានមួយៗទៅ គេបង្កើតជាចល័តតំបន់ ធ្វើស្រែម៉ាក្រុម ម៉ាកង ដូចថាប្រមូលម៉ាស្រុកព្រះនេត្រព្រះគេដាក់ គេជ្រើសរើសកម្លាំងណាខ្លាំងៗឲ្យនៅទៅ ដូចថាស្រុកសេរីសោភ័ណគេឲ្យនៅម៉ាកន្លែងទៅ ស្រុកភ្នំស្រុក គេឲ្យនៅម៉ាកន្លែងទៅ។ គេជ្រើសរើសកម្លាំងចំនួនម៉ាស្រុកៗ ព្រះនេត្រព្រះគេជ្រើសរើស ពួកខ្ញុំម៉ាចល័តព្រះនេត្រព្រះទៅ គេដកមកវិញតាមភូមិៗគេប្រជុំយើង គេហៅកម្លាំងប្រជុំ យើងអ្នកមាំទាំគេហៅចូល គេហៅឈ្មោះចេញ។

ដានី ៖ ចុះទំនប់អាងត្រពាំងថ្មនឹង គេយកធ្វើអីដែរ?

ណម ៖ គេធ្វើអាងទឹក។

ដានី ៖ ធ្វើអាងទឹក?

ណម ៖ ចា៎! ស្ពានទឹកគេបើកបង្ហូរចេញចូល ពេលខែភ្ជុំបិណ្យគេទៅលេងកក្រើងនោះ។

ដានី ៖ ចុះមីងរៀបការឆ្នាំណា?

ណម ៖ ខ្ញុំរៀបការឆ្នាំ៧៩។

ដានី ៖ បែកយួនចូលហើយ?

ណម ៖ ចា៎! យួនចូលខែយើងច្រូតស្រូវ ខែខ្មែរគេហៅខែមាឃ បើខែខ្មែរគេហៅខែមាឃធំ ខ្ញុំការខែវស្សា ចូលឆ្នាំរួចហើយ។

ដានី ៖ ការតាមប្រពៃណីត្រឹមត្រូវ មិនមែនការ ជំនាន់ប៉ុលពត?

ណម ៖ អត់ទេ កាលសម័យខ្ញុំការ វាអត់មានមេក្រូមាន ភ្លេងមាន តែសម័យយើងអត់ចាយលុយចាយអង្ករ គេចងដៃជាស្រូវម៉ាតៅម្នាក់ អង្ករ១០-២០កំប៉ុងទៅ ភ្លេងគេយកអង្ករទៅ ទៅច្រូតគេយកអង្ករទៅ ព្រោះសម័យនោះអត់ទាន់មានលុយចាយទេ។ គេចាយអង្ករ ជាមាស១០កំប៉ុងម៉ាហុន ជាមាស ប៉ះណាគេចងម៉ាតៅ យើងយកមកកិនស៊ី មេក្រូគេយកស្រូវម៉ាបាវក៏យើងឲ្យគេទៅ ជាង...(ស្តាប់មិនបាន) គេយកស្រូវម៉ាតៅឲ្យគេទៅ។

ដានី ៖ ចុះមីងពេលដែលមីងមកនៅគពាដើម ធ្វើចល័តធ្វើអីនឹង ហូបចុកអីគ្រប់គ្រាន់ដែរ?

ណម ៖ បរិបូរ ស៊ីម៉ាថ្ងៃ៣ពេល។

ដានី ៖ ម៉ាថ្ងៃ៣ពេល?

ណម ៖ ចុះពួកខ្ញុំធ្វើស្រែបាន ម៉ាឆ្នាំតិចៗណាស់ រាប់ពាន់បាវធ្វើបានច្រើនណាស់ ដីងតែធ្វើបានច្រើន។

ដានី ៖ តែម៉ាកន្លែងគ៣ដើម មានបាត់គេចាប់យកទៅដែរ?

ណម ៖ នៅ មានដូចប្រវត្តិខ្ញុំ មានអ្នកថ្មីម្នាក់ គាត់នោះស្អាតណាស់ ឲ្យអាវខ្ញុំមួយ បានតែ៣ថ្ងៃគេយកគាត់ទៅសម្លាប់ គាត់នោះស្រឡាញ់ខ្ញុំស្រឡាញ់ គាត់នោះវ័យកណ្តាល ប៉ុន្តែគាត់ការ ។ គាត់វ័យកណ្តាល ប៉ុន្តែប្តីគាត់អ្នកបុណ្យសក្តិ គាត់បានប្តីរួច ស្រុកអាពតវាចូលគាត់បែកបាក់ប្តី គាត់នៅនេះ នៅស្រមោល ដល់គាត់មកនៅចល័ត គាត់នៅជុំខ្ញុំនោះឯង គាត់និយាយសុទ្ធតែការរស់នៅ....គាត់អ្នកចេះណាស់ គាត់បងខ្ញុំ៣ឆ្នាំ៤ឆ្នាំនោះឯង ក្មេង គាត់ឲ្យអាវខ្ញុំមួយ គាត់និយាយអាវ១ឡេវខ្មៅ អាវនោះដែលខ្ញុំបានប្តីក៏ខ្ញុំកាត់ធ្វើឡេវមុខពាក់ ។ ខ្ញុំយកទៅលរទៅ គាត់និយាយប្រវត្តិ ។

ដានី ៖ ឥឡូវនៅទេ អាវនឹង?

ណម ៖ អត់ទេ ឡេវអាវឡើងដាច់ ឲ្យអាវខ្ញុំមួយ គាត់ស្រឡាញ់ខ្ញុំ គាត់ថាប្អូនឯងធ្វើការនៅរស្ងៀ គាត់ និយាយបានតែ៥ថ្ងៃ គេយកគាត់ទៅសម្លាប់ ។

ដានី ៖ ហេតុអីបានគេយកគាត់ទៅសម្លាប់?

ណម ៖ គេស៊ើបប្រវត្តិទៅ មានដូចថាអ្នកជួបគាត់រាយការណ៍ថាគាត់ប្រពន្ធលោកអ្នក បានជានិយាយជីវិតគាត់ឆ្លងមិនផុតទេ ឆ្នាំ៧៧ ។

ដានី ៖ កាលនឹងយាយចែមគាត់មក?

ណម ៖ បាត់តាវ៉ាល់ តាមោង ស្លាប់បណ្តើរ១ លោកប៊ុន សោម មេទ័ព ក្រែងលរ គាត់ធ្វើមេទ័ពលោក ប៊ុន សោម កូនគាត់ឈ្មោះអាប៊ុន សុង ក៏គេវៃចោលនៅគ៣ដើម នៅទំនប់នេះចប់គេវៃចោល អានោះនៅកំលោះ ។ អានោះបើសិននៅកូនខ្មែរ មានអ្នកនាំរត់វារត់ទៅតាមគ្នាមិនដឹងទីដៅ ចុះកូនអ្នកធំនោះ អូ!ធ្វើការខ្លាំងណាស់ អានោះក៏គេវៃចោលនៅកន្លែងគ៣ដើម ។ យាយប៉ុនោះម្នាក់ទៀត ហើយអាមួយនោះនៅខាងជើងវត្តនោះក៏គេវៃចោល.....(ស្តាប់មិនបាន) ។

ដានី ៖ ឲ្យតែអ្នកដែលធ្វើការធំ១ពីជំនាន់លន់ នល់ ដឹងថាគេវៃចោល?

ណម ៖ ចា៎! ចុះកូនលោក ប៊ុន សោម១ ធំនោះ ។

ដានី ៖ ចុះអ្នកយើងអត់ធ្វើការអី យើងធ្វើស្រែធ្វើអី អត់អីទេ?

ណម ៖ អត់អីទេ កុំឲ្យតែខ្ជិលគេចវេស ហើយនឹងយើងខុសសីលធម៌ ។

ដានី ៖ ចុះមីងនៅកន្លែងគ៣ដើម គោករំចេក រហូតដល់យួនចូល?

ណម ៖ ចា៎! យួនចូលក៏ពួកប្រធានអីរត់ទៅជាមួយពួកយាយចែក ក៏ពួកខ្ញុំមកផ្ទះ ។

ដានី ៖ មីងអត់រត់ទៅជាមួយយាយថែម?

ណម ៖ ខ្ញុំនាំគ្នាមកផ្ទះ ។ កាលនោះ គេយកគោរទេះគ្រប់គ្នា ខ្ញុំអត់យកអីទេ ដើររកតែម៉ែខ្ញុំ ២នាក់ មីដែលងាប់ ។ ដើរមកដល់ដប់ឃើញគេរែក១ឡើងប្រៀប រួចយោធា នោះដេញបាញ់ ប្រជាជនវារត់ យោធានៅចក្រី ។ ខ្ញុំដើរនាំគ្នាដើរមក មានអា២នាក់នោះ នៅឈ្នួលគេយក គោម៉ានីម រទេះមួយ គេបរមក ខ្ញុំដើរកន្ទេងព្រៃមាន់ក៏យប់ជ្រៅ ខ្ញុំអង្គុយកន្ទេងយាយជីក នោះពីដើមមិញយាយជីនោះក៏រូបសំណាក់តែមួយ ខ្ញុំអង្គុយ១ដល់ខែរះរៀងវាភ្លឺ ដើរយប់ យើងជិះមកជាមួយឡានយួនចូលមកឡើងប្រៀប ។ ឡានយួនមកពីកើត អត់មានមកពីលិច ទេ ។ មកពីកើតទាំងអស់ ។

ដានី ៖ មកពីខាងសៀមរាបមក?

ណម ៖ ចាំ!

ដានី ៖ ខាងក្រឡាញ់ខាងអីនឹង?

ណម ៖ ដឹងមកពីខាងណាទេ ដឹងឡានមកពីកើតរហូត ។

ដានី ៖ ចឹងមីងខ្ញុំដូចជាអស់សំនួរត្រូវសួរនាំមីងទៀតហើយ មីងមានអីចង់បន្ថែមនូវអ្វីដែលខ្ញុំអត់បាន សួរនាំ?

ណម ៖ ទេ! អត់មានអីទេ ។

ដានី ៖ ចឹងខ្ញុំអរគុណមីងច្រើន ។

ណម ៖ ចាំ!

«ចប់»